**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economies**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# អានុភាព នៃការលែងលះ

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមិនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ **ឆយ ចំរើន**

សាស្ត្រាចារ្យណែនាំ៖
បណ្ឌិត **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ៖ **នីតិសាស្ត្រ**
ជំនាន់ទី ២២

ឆ្នាំចូលសិក្សា៖ ២០១៧
ឆ្នាំសរសេរសារណា៖ ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economies**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# អានុភាព នៃការលែងលះ

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមិនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ **ឆយ ចំរើន**

សាស្ត្រាចារ្យណែនាំ៖
បណ្ឌិត **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ៖ **នីតិសាស្ត្រ**
ជំនាន់ទី ២២

ឆ្នាំចូលសិក្សា៖ ២០១៧
ឆ្នាំសរសេរសារណា៖ ២០២២

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឆយ ចំរើន** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ ឆ្នាំសិក្សា ២០១៧-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមថ្លែងនូវកតញ្ញូតាធម៌ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក **ឆិត្យ វណ្ណា** និងអ្នកម្ដាយ **ឃួន ឃី** ដែលលោកទាំងទ្វេរបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំ និងផ្ដល់ដំបូន្មានល្អៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងហ៊ានលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត លះបង់គ្រប់យ៉ាង ដើម្បីឱ្យកូនបានសិក្សាក្រេបជញ្ជក់យកនូវចំណេះដឹង និងទំនុកបម្រុងគ្រប់សព្វបែបយ៉ាងដល់រូបកូន ទាំងផ្នែកស្មារតី និងសម្ភារៈតាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ក្នុងគោលបំណងចង់ឱ្យរូបកូនក្លាយជាបញ្ញាជនមួយរូប ដែលអាចជាកម្លាំងចលករក្នុងការជួយលើកស្ទួយដល់សង្គមជាតិយើង។ ក្នុងនាមខ្ញុំជាកូនគ្មានអ្វីតបស្នងដើម្បីឱ្យសាកសមនោះទេ គឺមានតែការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ឱ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីកុំឱ្យកម្លាំងញើសឈាម ដែលលោកអ្នកមានគុណទាំងពីរ បានចំណាយរសាត់បាត់បង់ដោយឥតន័យ។ ទន្ទឹមនឹងនេះរូបកូនសង្ឃឹមថាលោកអ្នកមានគុណទាំងពីរនឹងសប្បាយចិត្ត និងមានមោទនភាពលើលទ្ធផល ដែលរូបកូនបានខិតខំប្រឹងប្រែងអស់រយៈពេលជាច្រើនឆ្នាំកន្លែងមកនេះ។

**ឯកឧត្តម លុយ ចណ្ណា** និងសាស្ត្រាចារ្យ គ្រប់រូបនៃសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយបង្ហាត់បង្ហាញ តាមរយៈការបង្រៀនយ៉ាងយកចិត្តទុកដាក់ និងអស់ពីកម្លាំងកាយចិត្តដល់រូបនាងខ្ញុំ រយៈពេល ៤ឆ្នាំកន្លងមកនេះ។

លោកសាស្ត្រាចារ្យ **ទេព សុខ** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ ណែនាំ បង្ហាត់បង្ហាញ ពន្យល់ រំលឹក កែតម្រូវ ព្រមទាំងបង្កភាពងាយស្រួលដល់ការតម្រង់ទិសក្នុងការសរសេរសារណានេះឡើង។

ជាចុងក្រោយ នាងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិផងទាំងពួង ដែលមាននៅលើលោកនេះ ដើម្បីតាមជួយថែរក្សាអស់លោកអ្នកមានគុណទាំងឡាយឱ្យជួបតែសេចក្ដីសុខ សេចក្ដីចម្រើន គ្រប់ពេលវេលាកុំបីឃ្លៀងឃ្លាតឡើយ។

## **អារម្ភកថា**

ក្រោយបានសិក្សា និងឆ្លងកាត់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ អស់រយៈពេល ០៤ឆ្នាំ នៃសាកលវិទ្យាល័យ **ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** នូវមុខវិជ្ជាជាច្រើន ដែលមានទាក់ទងនឹងវិស័យច្បាប់ នៅក្នុងប្រទេសកម្ពុជា ហើយអ្វីដែលពិសេសនោះ គឺទាក់ទងនឹង **ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី** និង **ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ** ដែលធ្វើឱ្យនាងខ្ញុំបានទទួលចំណេះដឹងយ៉ាងទូលំទូលាយ ប្រកបដោយភាពច្បាស់លាស់ ក្រោមការយកចិត្តទុកដាក់ពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនានា។ ដោយមានការជ្រោមជ្រែង និងការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្ត ទាំងអស់នេះហើយទើបធ្វើឱ្យនាងខ្ញុំអាចឈានមកដល់ការចងក្រងសារណាថ្នាក់បរិញ្ញាបត្រជំនាន់ទី២២ ដើម្បីចូលរួមចំណែកក្នុងការចែករំលែកចំណេះដឹងមួយចំនួន ដល់និស្សិតជំនាន់ក្រោយផង។

ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ នាងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងទៅនឹង **ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី** និង**ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ** ដែលមានប្រធានបទ “**អានុភាព នៃការលែងលះ**”។ ការជ្រើសរើសប្រធានបទនេះឡើងមកគឺដើម្បីឱ្យនិស្សិតផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ គ្រប់រូបបានយល់ដឹងកាន់តែច្បាស់អំពី **សញ្ញាណទូទៅនៃការលែងលះ លំហូរនីតិវិធីនៃការលែងលះរបស់តុលាការ និងអានុភាពនៃការលែងលះ** អោយកាន់តែលម្អិត។

នាងខ្ញុំសង្ឃឹមថា សារណាមួយនេះនឹងអាចជាឯកសារជំនួយស្មារតី និងជាឯកសារសម្រាប់សិក្សាស្រាវជ្រាវរបស់មិត្តនិស្សិត ជាពិសេស គឺនិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ហើយលើសពីនេះទៅទៀត នាងខ្ញុំចង់បន្សល់ទុកនូវស្នាដៃ ដើម្បីជាការចងចាំមួយដែលមិនអាចបំភ្លេចបាន ដែលនាងខ្ញុំក៏ធ្លាប់ជាអតីតនិស្សិតនៃសាកលវិទ្យាល័យ **ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** នេះផងដែរ។

នាងខ្ញុំ ក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងឡាយ ក្នុងប្រការណាមួយ ដោយអចេតនា នូវពាក្យពេចន៍ ក៏ដូចជាអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ហើយនាងខ្ញុំនឹងទទួលស្វាគមន៍ជានិច្ចនូវរាល់ការរិះគន់ ក្នុងន័យស្ថាបនានូវចំណេះដឹងរបស់នាងខ្ញុំ ដើម្បីបំពេញចំណុចខ្វះខាតទាំងនោះឱ្យមកជាល្អគ្រប់ជ្រុងជ្រោយវិញ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ...................................................................................................... ១

## ជំពូកទី១
## ការលែងលះ

**១.១. សញ្ញាណទូទៅ នៃការលែងលះ** ........................................................................ ៤

១.១.១. និយមន័យនៃអាពាហ៍ពិពាហ៍ ......................................................................... ៤

១.១.២. និយមន័យនៃការលែងលះ ............................................................................ ៤

**១.២. ប្រភេទ នៃការលែងលះ** ................................................................................ ៥

១.២.១. ការលែងលះដោយការព្រមព្រៀង ..................................................................... ៥

១.២.២. ការលែងលះដោយមិនមានការព្រមព្រៀង ........................................................... ៦

**១.៣. មូលហេតុ នៃការលែងលះ** ............................................................................. ៧

១.៣.១. បានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ ............................................................ ៧

១.៣.២. បានបោះបង់សហព័ទ្ធចោល ............................................................................ ៧

១.៣.៣. ករណីមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ឆ្នាំ .............................. ៧

១.៣.៤. ករណីសហព័ទ្ធបានរស់នៅបែកគ្នា ..................................................................... ៨

១.៣.៥. ករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ............................................. ៨

១.៣.៦. មូលហេតុដែលមានមិនចែងក្នុងច្បាប់ .................................................................. ៩

## ជំពូកទី២
## នីតិវិធីនៃការលែងលះ

**២.១ នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀងលែងលះ** ........................................ ១១

២.១.១ នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀងលែងលះ ........................................ ១១

២.១.១.១. កិច្ចព្រមព្រៀងលែងលះ ................................................................................ ១១

២.១.១.២. ពាក្យសុំលែងលះ ...................................................................................... ១២

២.១.១.៣. ពាក្យសុំជាលាយលក្ខណ៍អក្សរ ........................................................................ ១២

២.១.១.៤. ពាក្យសុំដោយផ្ទាល់មាត់ ................................................................................ ១៣

២.១.១.៥.សមត្ថកិច្ចដោះស្រាយ ..........................................................................................................................១៣
២.១.១.៦. ការចេញដីកាសម្រេច ..........................................................................................................................១៦
**២.២ នីតិវិធីនៃការលែងលះ ក្នុងករណីមានពាក្យបណ្តឹងលែងលះ** ..........................................................................១៧
២.២.១. តុលាការមានសមត្ថកិច្ច ..........................................................................................................................១៧
២.២.២. បណ្តឹងលែងលះ ..........................................................................................................................១៧
២.២.៣. ការផ្សះផ្សារដោយតុលាការ ..........................................................................................................................១៨
២.២.៤. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ..........................................................................................................................១៨
២.២.៥. ការទាញហេតុផលដោយផ្ទាល់មាត់ ..........................................................................................................................១៨
២.២.៦ សេចក្តីសម្រេចក្នុងរឿងលែងលះ ..........................................................................................................................១៩
២.២.៧. ការចាត់ចែងរក្សាការពារ ..........................................................................................................................១៩

## ជំពូកទី៣

## សិទ្ធិ និងកាតព្វកិច្ច ក្រោយពេលលែងលះ

**៣.១ សញ្ញាណទូទៅ អានុភាពនៃការលែងលះ** ..........................................................................................................................២១
៣.១.១. និយមន័យ អានុភាពនៃការលែងលះ ..........................................................................................................................២១
**៣.២. អានុភាពនៃការលែងលះ ចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ** ..........................................................................២១
**៣.៣. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ** ..........................................................................................................................២២
៣.៣.១. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ..........................................................................................................................២២
៣.៣.២. ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ ..........................................................................................................................២៣
**៣.៤. អានុភាពនៃការលែងលះចំពោះកូន** ..........................................................................................................................២៤
៣.៤.១ ទស្សនទាននៃអាហារកាតព្វកិច្ច ..........................................................................................................................២៤
៣.៤.២. បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ..........................................................................................................................២៥
៣.៤.៣. បុគ្គលដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ..........................................................................................................................២៦
៣.៤.៣.១.ការផ្គត់ផ្គង់ ការផ្លាស់ប្តូរ ឬការលុបចោល និងអនុប្បទានអាហារកាតព្វកិច្ច ..........................................................................២៦
**៣.៥. អាហារកាតព្វកិច្ច និងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន** ..........................................................................................................................២៨
៣.៥.១. អាហារកាតព្វកិច្ច និងអាហារកិច្ច ..........................................................................................................................២៨
៣.៥.២. ការគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច ..........................................................................................................................២៩

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៣៤
**អនុសាសន៍**............................................................................................................... ៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

និយាយពីការលែងលះ គឺសំដៅលើការរំលាយនូវចំណងគតិយុត្តរវាងប្តី និងប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ពេញច្បាប់។ រីឯអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យា ដែលកើតឡើងពីការសំដែងនូវឆន្ទៈដោយគ្មានវិការៈរវាងប្តី និងប្រពន្ធ។ ទើបកិច្ចសន្យានេះ បានក្លាយជាមូលដ្ឋានដ៏ចម្បង ដើម្បីជាការបង្កើតឱ្យមាននូវចំណងគតិយុត្តដ៏រឹងមាំមួយ។ ចំណងគតិយុត្តនេះនឹងធានាឱ្យបាននូវការផ្តល់ភាពជាក់លាក់ និងសុវត្ថិភាពគតិយុត្តគ្រប់គ្រាន់ដល់ប្តី និងប្រពន្ធ។ ក្នុងករណីមានភាគីណាមួយ ឬភាគីទាំងសងខាងនៃចំណងអាពាហ៍ពិពាហ៍ មានបំណងចង់រំលាយចោលនូវចំណងអាពាហ៍ពិពាហ៍មួយនេះឱ្យដាច់ស្រេច ហើយត្រូវបានទទួលស្គាល់ទាំងស្រុងនោះ ចាំបាច់ត្រូវតែគោរពតាមច្បាប់ដែលបានចូលជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។ តែបើក្រឡេកមើលតាមស្ថានភាពជាក់ស្តែងនៃច្បាប់វិញ បើបុរស-នារីណា គ្រាន់តែរៀបអាពាហ៍ពិពាហ៍ តាមបែបប្រពៃណី ទំនៀមទម្លាប់ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននោះ មិនអាចចាត់ទុកថាមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ជាប្តី-ប្រពន្ធឡើយ។ ការរួមរស់ជាប្តីប្រពន្ធ ដោយមិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់បែបនេះ ហៅថា អនីតិសង្វាស។ ការរស់នៅជាមួយគ្នាបែបអនីតិសង្វាស ប្រសិនបើ បុរស-នារីរូបណាអស់មនោសញ្ចេតនាលែងចង់រួមរស់ជាមួយគ្នាទៀត ពួកគេគ្រាន់តែសម្រេចចិត្តដើរចេញ បែកលំនៅឋានគ្នា និងលែងរួមរស់នៅជាមួយគ្នា ដោយគ្រាន់តែមានការដឹងឮពីឃុំ-សង្កាត់ជាការស្រេច តែចំពោះការបែងចែកទ្រព្យសម្បត្តិ និងអំណាចមេបាលើកូនវិញ មិនអាចដោះស្រាយត្រឹមឃុំ-សង្កាត់បានទេ ត្រូវតែដោះស្រាយតាមប្រព័ន្ធតុលាការដដែល។ តែយ៉ាងណាមិញ នៅក្នុងការសរសេរសារណារបស់នាងខ្ញុំ មិនបានសិក្សាទៅលើការរស់នៅជាមួយគ្នាបែបអនីតិសង្វាសនេះទេ។ ដោយនៅក្នុងការសរសេរសារណានេះ នាងខ្ញុំលើកយកតែករណីអាពាហ៍ពិពាហ៍ ដែលកើតឡើងដោយស្របច្បាប់ប៉ុណ្ណោះ គឺមានន័យថាមានការចុះសំបុត្រអាពិហ៍ពិពាហ៍ត្រឹមត្រូវ។

ក្នុងសង្គមបច្ចុប្បន្នយើងនេះ ករណីលែងលះតែងតែកើតឡើងជារៀងរាល់ថ្ងៃបង្កមកពីមូលហេតុផ្សេងៗគ្នាជាច្រើន។ ដូច្នេះរាជរដ្ឋាភិបាល បានបង្កើតច្បាប់ដើម្បីគ្រប់គ្រងឱ្យទាន់ពេលវេលា និងជាពិសេសនោះដើម្បីការពារគូភាគីទាំងសងខាងកុំឱ្យមានការរំលោភបំពានគ្នាទៅវិញទៅមក។ ថែមពីលើនេះទៀត រាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ និងផ្តល់សិទ្ធិទៅដល់ទីកន្លែងជាច្រើនផ្សេងទៀតទៅតាមមូលដ្ឋាន ក្នុងការសម្របសម្រួលដល់គូភាគី(ប្តី/ប្រពន្ធ)មុនពេលសម្រេចចិត្តចូលទៅដោះស្រាយតាមផ្លូវតុលាការ ដើម្បីជៀសវាងកុំឱ្យមានការខាតបង់ប្រយោជន៍ធំៗជាច្រើនដល់គូភាគី បណ្តាលមកពីការលែងលះនេះ។ ក៏ប៉ុន្តែបើក្រឡេកមើលអតីតកាលយើងដឹងហើយថា វិស័យយុត្តិធម៌នៅកម្ពុជា ត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង ដោយសារតែ

មានសង្គ្រាមស៊ីវិល តែទោះជាយ៉ាងនេះក្ដី ក៏រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន បានខិតខំប្រឹងប្រែងលើកស្ទួយវិស័យយុត្តិធម៌នេះឱ្យមានការរីកលូតលាស់ឡើងវិញផងដែរ។ ជាផ្លែផ្កាដែលបានកើតចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ហើយថែមទាំងមានការឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនជាមិត្តផងទៀតនោះ ជាលទ្ធផលកម្ពុជាបានអនុម័តក្រមរដ្ឋប្បវេណី កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៧ និងត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៣ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានតួនាទីសំខាន់ណាស់ ដោយបានកំពុងដើរតួនាទីជាមូលដ្ឋានគ្រឹះក្នុងការដោះស្រាយករណីលែងលះនានា ដែលកំពុងកើតឡើងជាបន្តបន្ទាប់នាពេលបច្ចុប្បន្ន។ ក្រៅពីក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានច្បាប់ផ្សេងៗទៀតដែលជាច្បាប់ជំនួយ ក្នុងការដោះស្រាយករណីលែងលះ រួមមាន ច្បាប់ស្ដីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ច្បាប់ស្ដីពីឯកពន្ធភាព ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៦ និងច្បាប់ស្ដីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៦ រួមទាំងច្បាប់នានាផ្សេងៗទៀតដែលពាក់ព័ន្ធ។

បច្ចុប្បន្នប្ដីប្រពន្ធជាច្រើនគូរ កំពុងមានបញ្ហាលែងលះគ្នាបណ្ដាលមកពីកត្តាផ្សេងៗគ្នា ដែលធ្វើឱ្យសង្គមមានការព្រួយបារម្ភជាខ្លាំង តែទោះជាយ៉ាងណាក្ដី ក៏ពួកគេបានសម្រេចចិត្តហើយថាពួកគេនឹងលែងលះគ្នាឱ្យដាច់ស្រេចទៅតាមផ្លូវតុលាការ ដើម្បីកុំឱ្យមានបញ្ហានៅថ្ងៃក្រោយ។ ការដោះស្រាយតាមប្រព័ន្ធតុលាការ ប្ដីប្រពន្ធតែងតែមានការភ័យខ្លាច ទៅលើប្រព័ន្ធយុត្តិធម៌ ជាពិសេសទៅលើស្ថាប័នតុលាការ ខ្លាចថាស្ថាប័ននេះមានការដោះស្រាយដោយមានភាពលំអៀង មិនស្របតាមនីតិវិធីច្បាប់ និងគ្មានតម្លាភាព ជាហេតុធ្វើឲ្យមានផលវិបាកចំពោះពួកគេក៏ដូចជាសង្គមកាន់តែខ្លាំងឡើង។ ហេតុផលទាំងនេះ ក៏ដោយសារស្ថាប័នតុលាការ ធ្វើការនៅខ្វះចន្លោះ ជាពិសេសមន្ត្រីមួយចំនួនដែលពាក់ព័ន្ធ ធ្វើការនៅក្នុងរឿងក្ដីលែងលះនេះតែម្ដង ដែលតែងតែធ្វើការខ្ជីខ្ជា។ តើមូលហេតុចម្បងធំៗអ្វីខ្លះ ដែលនាំឱ្យមានករណីលែងលះ? តើដំណើរការ និងនីតិវិធីនៃការលែងលះ ប្រព្រឹត្តទៅយ៉ាងដូចម្ដេច? តើសេចក្ដីសម្រេចរបស់តុលាការ មានអានុភាពទៅលើអ្វីខ្លះ?

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីចូលរួមចំណែកបង្កើននូវចំណេះដឹង ព្រមទាំងដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីករណីលែងលះ សិទ្ធិ និងកាតព្វកិច្ចក្រោយពេលលែងលះ។ ម្យ៉ាងទៀតការស្រាវជ្រាវនេះ ក៏បានធ្វើឱ្យនាងខ្ញុំយល់ដឹងពីករណីលែងលះមួយកម្រិតទៀតផងដែរ។ មិនតែប៉ុណ្ណោះ វាក៏ជាឯកសារមួយសម្រាប់តម្កល់ទុកក្នុង បណ្ណាល័យនៃសាកលវិទ្យាល័យ ដើម្បីឱ្យនិស្សិតជំនាន់ក្រោយអាចធ្វើការសិក្សាជាបន្ទាប់បន្សំថែមទៀត។ តែទោះបីជាយ៉ាងណា ចំពោះគោលបំណងគ្រឹះ និងគោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវ គឺផ្ដោតយ៉ាងសំខាន់ទៅលើ មូលហេតុនៃការលែងលះ នីតិវិធីនៃការលែងលះ ព្រមទាំង សិទ្ធិ

និងកាតព្វកិច្ចក្រោយពេលលែងលះតែប៉ុណ្ណោះ។ កាលដែលកំណត់អំពីដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវដែលបានរៀបរាប់ខាងលើនេះ ធ្វើឱ្យនាងខ្ញុំកាន់តែមានភាពងាយស្រួលក្នុងការស្រាវជ្រាវ។

ការស្រាវជ្រាវមួយនេះ មានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋខ្មែរទូទៅ និងអ្នកសិក្សាគ្រប់មជ្ឈដ្ឋានអាចស្វែងយល់ឱ្យកាន់តែស៊ីជម្រៅទៅលើ ករណីលែងលះ ក៏ដូចជាអានុភាពនៃការលែងលះ ព្រមទាំងនិស្សិតទាំងឡាយដែលមានបំណងចង់ស្វែងយល់ពីប្រធានបទនេះ។

មុនឈានដល់ការបកស្រាយប្រធានបទ នាងខ្ញុំបានធ្វើការបែងចែកសារណានេះ ជាបីជំពូកមាន៖

**ជំពូកទី១ ការលែងលះ**

១.១ សញ្ញាណទូទៅ នៃការលែងលះ

១.២ ប្រភេទនៃការលែងលះ

១.៣ មូលហេតុ នៃការលែងលះ

**ជំពូកទី២ នីតិវិធីនៃការលែងលះ**

២.១ នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀងលែងលះ

២.២ នីតិវិធីនៃការលែងលះ ក្នុងករណីមានពាក្យបណ្តឹងលែងលះ

**ជំពូកទី៣ សិទ្ធិ និងកាតព្វកិច្ច ក្រោយពេលលែងលះ**

៣.១ សញ្ញាណទូទៅ អានុភាពនៃការលែងលះ

៣.២ អានុភាពនៃការលែងលះ ចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ

៣.៣ អានុភាពនៃការលែងលះ ចំពោះទ្រព្យសម្បត្តិ

៣.៤ អានុភាពនៃការលែងលះ ចំពោះកូន

៣.៥ អាហារកាតព្វកិច្ច និងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន

# ជំពូកទី១
# ការលែងលះ

# ជំពូកទី១

# ការលែងលះ

## ១.១. សញ្ញាណទូទៅ នៃការលែងលះ

ជាទូទៅអាពាហ៍ពិពាហ៍កើតចេញពីការស្ម័គ្រចិត្តរបស់មនុស្សពីរនាក់។[1]

ចំណងអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងដោយគោរពតាមលក្ខខណ្ឌច្បាប់ត្រឹមត្រូវ យ៉ាងណាមិញ ដើម្បីរំលាយនូវចំណងអាពាហ៍ពិពាហ៍មួយដែលបានកើតឡើង ក៏ត្រូវតែអាស្រ័យទៅលើលក្ខខណ្ឌច្បាប់ដែលកំណត់តម្រូវផងដែរ ស្ថានភាពនេះហើយដែលនាំឱ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។ ការលែងលះគ្នាត្រូវបានគេចាត់ទុកជាសាលក្រម ឬសាលដីការបស់តុលាការ ដែលប្រកាសថា ចំណងអាពាហ៍ពិពាហ៍ដែលបានគោរពទៅតាមផ្លូវច្បាប់ត្រូវបានបញ្ចប់ ជាហេតុធ្វើឲ្យសហព័ទ្ធទាំងពីរលែងមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាតទៅទៀត។

សាលាក្រម ឬសាលដីកា ជាសេចក្តីសម្រេចរបស់តុលាការ ដែលធ្វើការពិចារណាទៅលើភស្តុតាងដែលជាប់ពាក់ព័ន្ធ និងបញ្ហាដែលតុលាការត្រូវសម្រេចក្នុងរឿងវិវាទ នៃអាពាហ៍ពិពាហ៍។[2]

### ១.១.១. និយមន័យ នៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាពិសេសមួយ ដែលខុសពីកិច្ចសន្យាធម្មតា។ ចំពោះកិច្ចសន្យាធម្មតាឱ្យតែសំណើរ និងស្ទីការត្រូវគ្នា គឺកិច្ចសន្យាត្រូវបានបង្កើតឡើង ទោះបីជាត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬ មិនធ្វើជាលាយលក្ខណ៍អក្សរក៏ដោយ ក៏ប៉ុន្តែកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឱ្យប្រិតបៀងបំផុត ត្រូវគោរពតាមប្រពៃណី និងស្របតាមគោលការណ៍នៃច្បាប់ មានន័យថាកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ មិនអាចធ្វើដោយផ្ទាល់មាត់បានទេ ថ្វីបើមានសំណើសុំរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ហើយបើមិនគោរពតាមលក្ខខណ្ឌត្រឹមត្រូវទេ កិច្ចសន្យាអាពាហ៍ពិពាហ៍ មិនត្រូវបានបង្កើតឡើយ។[3]

### ១.១.២. និយមន័យ នៃការលែងលះ

ការលែងលះ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តី និងប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ពេញច្បាប់។[4] ហើយការលែងលះនឹងធ្វើឱ្យមានការផ្លាស់ប្តូរឋានៈបុគ្គលពាក់ព័ន្ធ នៅក្នុងរង្វង់ញាតិ និងសង្គម។ ការផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងប្តី និងប្រពន្ធ ក្នុងន័យនេះ គឺសំដៅលើការរំដោះខ្លួនឱ្យរួចពីចំណង នៃទំនាក់

---

[1] មាត្រា ៣ (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

[2] ទំព័រ ១៨៥ គន យឿន (នីតិ គ្រួសារ និង អាពាហ៍ពិពាហ៍ ២០១៣)

[3] មាត្រា ៩៥៥ (ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

[4] មាត្រា ៣៨ (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

ទំនងអាពាហ៍ពិពាហ៍ ដែលខ្លួនធ្លាប់ជាសហព័ទ្ធកន្លងមក ហើយចំពោះករណីយកិច្ចស្មោះត្រង់ក៏ត្រូវរលត់ទៅតាមការផ្តាច់ចំណងអាពាហ៍ពីពាហ៍ ដែលន័យនេះសំដៅទៅលើសហព័ទ្ធណាម្នាក់ អាចរៀបអាពាហ៍ពិពាហ៍សារជាថ្មី ជាមួយអ្នកណាម្នាក់ផ្សេងទៀតបាន។[5]

## ១.២. ប្រភេទ នៃការលែងលះ

ប្តី ប្រពន្ធ អាចធ្វើការលែងលះគ្នាដោយមានការព្រមព្រៀងគ្នាទាំងសងខាងដោយគ្មានកំហុសរបស់ប្តី ឬប្រពន្ធឡើយ។ ផ្ទុយទៅវិញក៏មានប្តី ប្រពន្ធគូរខ្លះ បានបង្កើតកំហុសជារឿយៗ ដោយអត់ទ្រាំពុំបាន ភាគីម្ខាងនៃសហព័ទ្ធរបស់ពួកគេបានដាក់ពាក្យប្តឹងសុំលែងលះ។ ហេតុនេះហើយ គេបានចែកការលែងលះជាពីរប្រភេទ គឺការលែងលះគ្នាដោយមានការព្រមព្រៀង ឬជាទ្វេភាគី និងការលែងលះគ្នាដោយមិនមានការព្រមព្រៀង ឬជាឯកតោភាគី។

### ១.២.១. ការលែងលះ ដោយការព្រមព្រៀង ឬជាទ្វេភាគី

ក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មីត្បិតតែ គឺជាការព្រមព្រៀងរវាងបុរស និងស្ត្រី ដែលសច្ចាថានឹងរួមរស់ក្នុងជីវិតជាស្វាមីភរិយាដែលប្រកបទៅដោយសុភមង្គលក៏ពិតមែន ប៉ុន្តែការសច្ចាស្បថស្បែនោះ ក៏នឹងមិនអាចឋិតថេរជានិរន្តដែរ។ សហព័ទ្ធមួយចំនួនដែលបានរួមរស់ជាមួយគ្នា ខ្លះក៏ទទួលបាននូវភាពសុខដុមរមនា ប៉ុន្តែសហព័ទ្ធខ្លះទៀតមានភាពរកាំរកូសជាច្រើននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ វាអាចបណ្តាលមកពីការមិនចុះសម្រុងនឹងគ្នា ការមិនចេះអធ្យាស្រ័យគ្នាទៅវិញទៅមក មានចិត្តគំនិតផ្ទុយគ្នា ដែលជាហេតុធ្វើឱ្យអ្នកទាំងពីរ មានផលវិបាកក្នុងការរស់នៅជាមួយគ្នាបន្តទៀត។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺការលែងលះជាទ្វេភាគី គឺមានភាពល្អប្រសើរ ដោយហេតុថាការសម្រេចចិត្តថានឹងធ្វើការលែងលះ មិនមែនជាឆន្ទៈតែម្ខាងរបស់សហព័ទ្ធណាមួយឡើយ តែផ្ទុយទៅវិញ គឺសហព័ទ្ធទាំងពីរ មានឆន្ទៈដូចគ្នាក្នុងការលែងលះ។ ភាគីទាំងពីរមានការព្រមព្រៀងទាំងសងខាង ដោយមិនមានការបង្ខំពីសហព័ទ្ធម្ខាងណាឲ្យធ្វើការយល់ព្រមលែងលះនោះទេ។ ពោលគឺ ការលែងលះជាលក្ខណៈទ្វេភាគីនេះ ជាការសម្រេចចិត្តក្នុងការលែងលះ គឺស្ថិតនៅលើសហព័ទ្ធទាំងសងខាងផ្ទាល់តែម្តង ប្រសិនបើសហព័ទ្ធទាំងពីរ យល់ឃើញថាចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរត្រូវតែបញ្ចប់ដោយមិនអាចបដិទានបានឡើងវិញ នោះសហព័ទ្ធទាំងសងខាងអាចសម្រេចចិត្តធ្វើការលែងលះបាន។[6] បន្ទាប់ពីធ្វើការសម្រេចចិត្តដ៏ជាក់លាក់មួយហើយ សហព័ទ្ធដែលជាភាគី នៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យសុំលែងលះទៅតុលាការ ក្នុងករណីដែលភាគីទាំងសងខាងពិតជាបានព្រមព្រៀងគ្នា អំពីការលែងលះ

---

5 មាត្រា ៣៨ (ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩)

6 មាត្រា ៩៧៩ (ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

នោះពិតមែន។ ប៉ុន្តែតុលាការអាចឱ្យលែងលះបាន ក្រោយយល់ឃើញថា ភាគីទាំងសងខាងមានឆន្ទៈពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។ ជាការពិតណាស់ ទោះបីជាសហព័ទ្ធទាំងពីរបាននិយាយថាខ្លួនមានការព្រមព្រៀងគ្នាក្នុងការលែងលះក៏ពិតមែន ប៉ុន្តែមិនអាចយកជាការភ្លាមៗក្នុងការផ្តាច់ការចំណងអាពាហ៍ពិពាហ៍ឡើយ តុលាការនឹងធ្វើការស្វែងយល់អំពីសហព័ទ្ធទាំងពីរយ៉ាងម៉ត់ចត់ ប្រសិនបើតុលាការយល់ឃើញថាសហព័ទ្ធទាំងសងខាង ពិតជាមានឆន្ទៈស្របគ្នា ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ពិតប្រាកដមែន តុលាការនឹងអនុញ្ញាតឱ្យធ្វើការរំលាយចំណងអាពាហ៍ពិពាហ៍នោះបាន។[7]

ផ្ទុយទៅវិញ ទោះបីជាមានការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរក្តី ប្រសិនបើតុលាការយល់ឃើញថាការលែងលះគ្នានោះបណ្តាលឱ្យ ការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ កូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលមិនអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។

ឧទាហរណ៍៖ បន្ទាប់ពី សុខ បានរៀបអាពាហ៍ពិពាហ៍ ជាមួយ វីសា បានមួយឆ្នាំគត់ ពួកគាត់ទាំងពីរបានសម្រេចចិត្តលែងលះគ្នា ដោយហេតុថាជីវិតជាប្តីប្រពន្ធរបស់ពួកគាត់ បានអស់មនោសញ្ចេតនា ព្រមទាំងគ្មានភាពចុះសម្រុងនឹងគ្នា ហេតុផលសំខាន់ គឺរស់នៅជាមួយគ្នាគ្មានសុភមង្គល ដោយមានឆន្ទៈស្របគ្នារវាងពួកគាត់ទាំងពីរបែបនេះ វីសា បានដាក់ពាក្យស្នើសុំលែងលះទៅតុលាការ ដើម្បីផ្តាច់ចំណងអាពាហ៍ពិពាហ៍មួយនេះឱ្យដាច់ស្រេច បន្ទាប់ពីតុលាការបានស្វែងយល់ឃើញថាត្រឹមត្រូវតាមលក្ខខណ្ឌគ្រប់ហើយ តុលាការបានចេញសាលដីកាសម្រេចស្តីពីការលែងលះរវាង សុខ និង វីសា។

### ១.២.២. ការលែងលះ ដោយមិនមានការព្រមព្រៀង ឬជាឯកតោភាគី

ការលែងលះ ដោយមិនមានការព្រមព្រៀង ឬជាឯកតោភាគី គឺមានន័យថា សហព័ទ្ធម្ខាងអាចធ្វើការសម្រេចចិត្តសុំប្តឹងលែងលះពីសំណាក់ភាគីម្ខាងទៀតដោយឯកឯងបាន ដោយមិនចាំបាច់មានការព្រមព្រៀងពីសហព័ទ្ធ ដែលត្រូវប្តឹងនោះទេ ក្នុងករណីដែលសហព័ទ្ធនោះបានរកឃើញនូវកំហុស របស់សហព័ទ្ធណាម្ខាងបានប្រព្រឹត្តិនូវអំពើណាមួយមិនគប្បីទៅលើសហព័ទ្ធម្ខាងទៀត ជាដើមហេតុនាំឲ្យសហព័ទ្ធដែលជាជនរងគ្រោះដាក់ពាក្យបណ្តឹងលែងលះ ដើម្បីស្នើសុំឱ្យតុលាការរំលាយចំណងអាពាហ៍ពិពាហ៍ទៅតាមផ្លូវច្បាប់។ បណ្តឹងនេះកើតឡើងពីសហព័ទ្ធម្ខាងជាដើមបណ្តឹងក្នុងការទាមទារលែងលះ។

---

7 មាត្រា ៩៧៩ (ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

## ១.៣. មូលហេតុ នៃការលែងលះ

ប្រសិនបើភាគីមិនមានការព្រមព្រៀងគ្នាលែងលះទេ ការលែងលះអាចធ្វើទៅបាន លុះត្រាតែមាននូវមូលហេតុត្រឹមត្រូវយ៉ាងច្បាស់លាស់ដូចមានចែងក្នុងច្បាប់ ពោលគឺ៖

### ១.៣.១. បានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ

ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ អំពើនេះ ជាការរួមសេវនកិច្ចរវាងបុរស ដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។[8]

ឧទាហរណ៍៖ បុរសជាប្តីបានលួចចិញ្ចឹមស្រីកំណាន់ចិត្ត។

### ១.៣.២. បានបោះបង់សហព័ទ្ធចោល

ការបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ គឺជាការមិនបានរួមរស់ជីវភាពជាមួយគ្នា មិនសហការគ្នា មិនសង្គ្រោះគ្នាទៅវិញទៅមក ហើយដែលគេអាចទទួលស្គាល់ថា គូរភាគីមិនមានឆន្ទៈបន្តជីវភាពរស់នៅជាប្តីប្រពន្ធតទៅទៀតឡើយ។[9]

ឧទាហរណ៍៖ ក្រោយពីបានរៀបការរួចហើយ បុរសជាប្តីបានចុះចោលលំនៅឋាន ហើយទៅរស់នៅជាមួយឪពុកម្តាយរបស់គាត់វិញ ដោយមិនមានមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ នារីជាប្រពន្ធអាចធ្វើការដាក់ពាក្យបណ្តឹងលែងលះបាន។

### ១.៣.៣. ករណីមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ឆ្នាំ

បើមិនដឹងច្បាស់ថា សហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ឆ្នាំ ប្រសិនបើសហព័ទ្ធណាមួយបានចាកចេញ ឬចុះចោលសហព័ទ្ធម្ខាងទៀតដោយបាត់ដំណឹងសូន្យគ្មានបានផ្តល់ដំណឹងឱ្យសហព័ទ្ធម្ខាងទៀតឱ្យបានដឹងហើយបានចុះចោលជិតមួយឆ្នាំ សហព័ទ្ធណាមួយអាចដាក់ពាក្យសុំលែងលះ ឬជូនដំណឹងទៅឃុំ/សង្កាត់ឱ្យបានដឹងពីរឿងនេះបាន។[10]

ឧទាហរណ៍៖ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចហើយ មិនា បានចាកចេញពីប្រទេសកម្ពុជាទៅធ្វើការនៅបរទេស ក៏ប៉ុន្តែចាប់តាំងពីពេលចាកចេញទៅ គឺមិនអាចទាក់ទង មិនា បានទេហើយក៏ពុំមានដំណឹងពី

[8] មាត្រា ៩៧៨ (កថាខណ្ឌ១ ចំនុច ក ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)
[9] មាត្រា ៩៧៨ (កថាខណ្ឌ១ ចំនុច ខ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)
[10] មាត្រា ៩៧៨ (កថាខណ្ឌ១ ចំនុច គ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

មិនា ថានៅរស់ ឬ ក៏ស្លាប់ដោយសារមូលហេតុអ្វីមួយដែរ។ ប្រសិនបើបាត់ដំណឹងនេះលើសពី ១ឆ្នាំ ភរិយារបស់ មិនា អាចដាក់ពាក្យបណ្តឹងលែងលះបាន។

### ១.៣.៤. ករណីសហព័ទ្ធបានរស់នៅបែកគ្នា

កាលបើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ ដោយមិនបានរួមរស់នៅជាមួយគ្នាសោះ អស់រយៈពេលជាង ១ឆ្នាំ ទោះបីជាបានដំណឹងពីគ្នាក៏ដោយ ដែលទាំងនេះផ្ទុយទៅនឹងគោលបំណង នៃអាពាហ៍ពិពាហ៍ នោះសហព័ទ្ធ ណាមួយអាចដាក់ពាក្យបណ្តឹងសុំលែងលះបាន។ ក៏ប៉ុន្តែចំពោះការរស់នៅឆ្ងាយ ដោយសារការងារមិនចាត់ចូលទៅក្នុងចំណុចនេះទេ។[11]

ឧទាហរណ៍៖ ក្រោយពីបានរៀបការជាមួយគ្នារយៈពេល ២ ឆ្នាំ ចិន្តា និង ដានី បានសម្រេចចិត្តរស់នៅបែកគ្នា ដោយសារតែមានការអាក់អន់ស្រពន់ចិត្តនឹងគ្នាបន្តិចចន្តួច។ ប្រសិនបើអ្នកទាំងពីររស់នៅបែកគ្នាយ៉ាងដូច្នេះលើសពី ១ឆ្នាំ ភាគីណាម្ខាងអាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន។

### ១.៣.៥. ករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់

ករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទាន (សង ឬ ស្តារឱ្យដូចដើម) ឡើងវិញបាន។ នៅត្រង់ចំណុចនេះ គ្រាន់តែកំណត់ ពីមូលហេតុ នៃការលែងលះ ដោយទុកឱ្យចៅក្រមជាអ្នកវាយតម្លៃកំណត់ថា តើករណីណាខ្លះដែលឱ្យយើងជឿជាក់ថា អាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។ បែបនេះ ចៅក្រមនឹងពិចារណាដល់ស្ថានភាពនានាដែលកើតមានដូចជាសកម្មភាពអាកប្បកិរិយារបស់សហព័ទ្ធ នៅអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ឆន្ទៈរបស់ភាគីក្នុងការបន្តចំណងអាពាហ៍ពិពាហ៍ ស្ថានភាពសុខភាព ស្ថានភាពសេដ្ឋកិច្ច ជាដើម។[12]

ការលែងលះដោយឯកតោភាគីអាចនឹងធ្វើឡើងទៅបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ និងគ្រប់គ្រាន់បញ្ជាក់ថាសហព័ទ្ធទាំងពីរ ពុំអាចរស់នៅជាមួយគ្នាតទៅទៀតបាន មូលហេតុទាំងនោះរួមមានជាអាទិ៍៖[13]

- ការចុះចោលលំនៅសង្វាសដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបំរុងកូនសោះ។
- ប្រើអំពើវាយដំ ឃោរឃៅ ធ្វើទុក្ខបុកម្នេញ ប្រមាថមើលងាយធ្ងន់ធ្ងរ ចំពោះសហព័ទ្ធ ឬបុព្វញាត្តិរបស់សហព័ទ្ធនោះ។
- ចរិយាផ្ទុយពីសីលធម៌ និងការប្រព្រឹត្តអានាចារ

---

[11] មាត្រា ៩៧៨ (កថាខណ្ឌ១ ចំនុច ឃ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

[12] មាត្រា ៩៧៨ (កថាខណ្ឌ១ ចំនុច ង ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

[13] មាត្រា ៣៩ (ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩)

- អពលានុភាពនៃលិង្គ
- បែកគ្នាអស់រយៈពេលជាង ១ឆ្នាំ។

ឧទាហរណ៍៖ ក្នុងករណីនេះអាចមានច្រើន ដោយរួមបញ្ចូលទាំងការប្រើអំពើហិង្សាទៅលើសហព័ទ្ធ (ហិង្សាផ្លូវកាយ ផ្លូវចិត្ត ជាដើម) ផងដែរ ។

ករណីយល់ឃើញថាការទាមទារនោះផ្ទុយនឹងភាពសុចរឹត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែះលះដោយឆន្ទានុសិទ្ធិបាន ទោះបីមានមូលហេតុនៃការលែងលះ ដូចកំណត់ខាងលើក៏ដោយ។[14]

ឧទាហរណ៍៖ ភារី និង ករុណា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅឆ្នាំ២០០០ ហើយមានកូនជាមួយគ្នាចំនួនពីរនាក់។ លុះដល់ឆ្នាំ២០០៥ ដោយសារតែការអាក់អន់ស្រពន់ចិត្តនឹងគ្នាបន្តិចបន្តួច ករុណា បានចាកចេញពីផ្ទះ។ បន្ទាប់មក នៅឆ្នាំ២០០៦ ករុណា បានជួបនឹងនារីម្នាក់ផ្សេង ហើយក៏បានរស់នៅជាមួយគ្នានឹងនារីម្នាក់នោះ។ រហូតដល់ឆ្នាំ២០១៣ នេះ ករុណា បានដាក់ពាក្យបណ្តឹងលែងលះពី ភារី ដោយ ភារី មិនយល់ព្រមលែងលះពី ករុណា ឡើយ។ ក្នុងករណីនេះ ភារី និង ករុណា បានរស់នៅបែកគ្នាអស់រយៈពេល ៨ឆ្នាំក៏ពិតមែន តែតុលាការ អាចច្រានចោលការទាមទារលែងលះពីសំណាក់ ករុណា បានដោយតុលាការយល់ឃើញថាមូលហេតុការទាមទារនោះ ផ្ទុយនឹងភាពសុចរឹត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ ឧទាហរណ៍ដូចជា ភារី មិនមានការងារធ្វើ ហើយកូនទាំងពីររបស់នាង ជាអនីតជននៅឡើយ ចំណែកឯទ្រព្យសម្បត្តិទៀតសោត ក៏មិនសូវមានច្រើនដែលមិនអាចឱ្យ ភារី ផ្គត់ផ្គង់ជីវភាពគ្រួសារបានក្រោយពេលលែងលះ។

### ១.៣.៦. មូលហេតុដែលមានមិនចែងក្នុងច្បាប់

ក្រៅពីមូលហេតុដែលមានចែងក្នុង ច្បាប់ ក៏មានមូលហេតុជាច្រើន ដែលមិនអាចមើលរំលងបាននោះគឺ៖[15]

- **ភាពមិនស្មោះត្រង់** ជាកត្តាសំខាន់ដែលបណ្តាលឲ្យសហព័ទ្ធភាគច្រើនឈានទៅដល់ការលែងលះ និងជាការពិបាកទទួលយកបំផុត នៅក្នុងការរស់នៅប្រចាំថ្ងៃនៃជីវិតគ្រួសារ។ ភាពមិនស្មោះត្រង់នេះមិនបានសំដៅទៅលើតែទំនាក់ស្នេហាបែបត្រីកោណតែមួយមុខទេ វាអាចជាភាពមិនស្មោះត្រង់លើទ្រព្យសម្បត្តិផងដែរ។

[14] មាត្រា ៩៧៨ (កថាខណ្ឌទី២ ឬ កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

[15] សារណាបញ្ចប់ការសិក្សា ស្តីពីការលែងលះ និងផលប៉ះពាល់នៃការលែងលះ រៀបចំដោយ ហ៊ួ រ័ត្តនៈ និង ងឿន ពុទ្ធារី ឆ្នាំ២០២១

- **កង្វះចំណេះដឹង របស់ប្តីប្រពន្ធទាំងសងខាង** ជាកត្តាសំខាន់មួយដែលធ្វើឱ្យប្តីប្រពន្ធទាំងសងខាងជួបនៅបញ្ហាលែងលះគ្នា។ ករណីជាក់ស្តែង ដែលយើងមើលឃើញក្នុងសង្គមនាពេលបច្ចុប្បន្នទាក់ទងទៅនឹងចំណេះដឹងនេះ គឺប្តីប្រពន្ធដែលរស់នៅតាមទីជនបទផ្ទាល់តែម្តង ដែលពួកគាត់មានជីវភាពក្រីក្រ និងមិនបានបន្តការសិក្សាបានជ្រៅជ្រះធ្វើឱ្យពួកគាត់ខ្វះការអំណត់ចិត្ត បង្កជាអំពើហិង្សារហូតបណ្តាលឱ្យមានការលែងលះគ្នា។
- **កង្វះការប្តេជ្ញាចិត្ត** គឺជាកត្តាដែលកើតមានជាទូទៅក្នុងការលែងលះ និងការបែកបាក់គ្នា។ ប្រសិនបើយើងវិភាគលក្ខណៈនៃទំនាក់ទំនងរវាងគូរអាពាហ៍ពិពាហ៍ វាបង្ហាញឱ្យឃើញថាការប្តេជ្ញាចិត្ត គឺជាទិដ្ឋភាពដែលមិនអាចខ្វះបាន។ បើគ្មានឆន្ទៈក្នុងការប្តេជ្ញាចិត្តទេវាពិតជាលំបាកខ្លាំងណាស់ ក្នុងការរក្សាទំនាក់ទំនងជាមួយគ្នា។ ដូច្នេះគេសង្កេតឃើញថាគូស្វាមីភរិយាជាច្រើន ដែលសម្រេចចិត្តរៀបការដោយមិនមានការតាំងចិត្តគ្រប់គ្រាន់ទុកជាមុន ស្ទើរតែប្រែទៅជាការលែងលះដោយស្វ័យប្រវត្តិក្នុងឆ្នាំបន្តបន្ទាប់។
- **ការប្រច័ណ្ឌ** ជ្រុលហួសហេតុពេក ដោយមិនយកហេតុផលមកពិចារណាឱ្យបានត្រឹមត្រូវ ងាយនឹងប៉ះពាល់ដល់ការរស់នៅជាមួយគ្នាខ្លាំងណាស់។ ព្រោះកាលណាបើសិនជា មួយថ្ងៃៗ គិតតែពីរករឿង គិតតែពីខឹងគ្នានោះនឹងធ្វើឱ្យសហព័ទ្ធងាយនឹងបែកបាក់គ្នា រស់នៅផ្សេងគ្នា និងតែងតែមានបញ្ហារកាំរកូសនៅក្នុងគ្រួសារមិនចេះចប់មិនចេះហើយ រហូតឈានដល់ការលែងលះគ្នា។
- **រៀបការដោយមិនពេញចិត្ត** តាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន ពាក្យថានំមិនធំជាងនាឡិនៅតែបន្តប្រើប្រាស់ទៅលើកូនៗ នៅក្នុងគ្រួសារមួយចំនួនដដែល។ ដោយពួកគេរៀបការតាមចាស់ទុំរៀបចំបង្ខិតបង្ខំឲ្យរៀបការជាមួយមនុស្សដែលខ្លួនមិនបានស្រឡាញ់ កត្តានេះហើយដែលធ្វើឱ្យ ប្តីប្រពន្ធមួយចំនួន មិនបានស្វែងយល់ចិត្តគ្នាឱ្យបានស៊ីជម្រៅ មុនពេលសម្រេចចិត្តរៀបការជាមួយគ្នា ដែលជាហេតុនាំឲ្យសហព័ទ្ធងាយនឹងប្រេះស្រាំ។
- **ការប្រើប្រាស់គ្រឿងញៀន** ក្នុងសង្គមបច្ចុប្បន្នគ្រឿងញៀន គឺជាមូលហេតុធំណាស់ ដែលនាំឱ្យមានការបែកបាក់គ្នាក្នុងគ្រួសារ ព្រោះគ្រឿងញៀន បានបង្កឱ្យមានផលវិបាកចំពោះគ្រួសារ ក៏ដូចជាបាត់បង់សមត្ថភាពក្នុងការបំពេញការងារ បាត់បង់អាជីពការងារ ចំណូលគ្រួសារថយចុះ ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ និងបង្កឱ្យកិត្តិយសគ្រួសារអាប់ឱនជាដើម។ ក្រៅពីផលប៉ះពាល់ចំពោះគ្រួសារ គ្រឿងញៀនបានបង្កឱ្យមានផលវិបាកផ្សេងៗទៀតដល់សហគមន៍ និងសង្គមជាតិដូចជា បង្កឱ្យមានឧក្រិដ្ឋកម្ម

ឃាតកម្ម ចោរកម្ម អសន្តិសុខ ធនធានមនុស្សនៃសង្គមជាតិថយចុះ ការអភិវឌ្ឍន៍ក្នុងសង្គមមានការយឺតយ៉ាវ សីលធម៌សង្គមធ្លាក់ចុះទាប ប្រពៃណី វប្បធម៌ជាតិរេចរិល ប្រទេសជាតិទន់ខ្សោយជាដើម។

- **ការសេពគប់មិត្ត** ក្នុងសង្គមសម័យទំនើបនេះ ការសេពគប់មិត្តភក្តិ ជារឿងសំខាន់ណាស់ ដើម្បីទទួលបានសុភមង្គលក្នុងគ្រួសារទាំងមូល បើយើងយកបុគ្គលបែបណាជាមិត្ត នោះយើងប្រាកដជាមានទំនោរ តាមមិត្តនោះជាក់ជាមិនខាន។ ព្រោះបើមិត្តយើងជាមនុស្សដែលចូលចិត្តការដើរលេងផឹកស៊ី នោះយូរៗទៅ យើងនឹងក្លាយជាមនុស្សបែបនោះដែរជាមិនខាន ហេតុផលទាំងនេះ នឹងនាំឱ្យមានភាពរកាំរកូសបន្តិចម្តងៗក្នុងរង្វង់គ្រួសារទាំងមូល។

# ជំពូកទី២

# និតិវិធី នៃការលែងលះ

# ជំពូកទី២

# នីតិវិធី នៃការលែងលះ

## ២.១ នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀងលែងលះ

### ២.១.១ នីតិវិធីនៃការលែងលះ ក្នុងករណីមានការព្រមព្រៀងលែងលះ

ការលែងលះដោយមានការព្រមព្រៀងចំពោះភាគីទាំងពីរ គឺត្រូវតែមានឆន្ទៈក្នុងការលែងលះ។ សម្រាប់នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង គឺមានតែភាគីប្តី ប្រពន្ធទេ ដែលជាអ្នកចាប់ផ្តើមដំណើរការ។ ចំពោះនីតិវិធីដំបូងតាមរយៈការដាក់ពាក្យសុំលែងលះទៅតុលាការ គឺមិនមែនជារឿងក្តីដែលតុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹងដោយឆន្ទានុសិទ្ធិឡើយ មានន័យថា កម្មវត្ថុនៃការសម្រេច និងការចេញដីកាសម្រេច គឺភាគីជាអ្នកកំណត់នៅក្នុងពាក្យសុំ ហើយតុលាការអាចចាប់ផ្តើមជម្រះក្តីបានទាល់តែទទួលបានពាក្យសុំជាមុនសិន ដោយនៅក្នុងពាក្យសុំភាគីត្រូវមានកិច្ចព្រមព្រៀងលែងលះភ្ជាប់មកជាមួយផងដែរ។[16]

#### ២.១.១.១ កិច្ចព្រមព្រៀងលែងលះ

ដើម្បីបញ្ជាក់ពីឆន្ទៈត្រូវគ្នា ភាគីទាំងសងខាង នៃចំណងអាពាហ៍ពិពាហ៍ ត្រូវធ្វើកិច្ចព្រមព្រៀងលែងលះ។ កិច្ចព្រមព្រៀងលែងលះ គឺជាលិខិតមួយដែលគូភាគីទាំងពីរបានព្រមព្រៀងគ្នាធ្វើដោយឆន្ទៈ ដោយពុំមានការបង្ខិតបង្ខំពីភាគីម្ខាងណាឡើយ។ នៅក្នុងការព្រមព្រៀងលែងលះ គេអាចធ្វើបានតាមទម្រង់ពីរគឺ តាមទម្រង់ជាលាយលក្ខណ៍អក្សរ និងតាមទម្រង់ផ្ទាល់មាត់។

ទម្រង់ជាលាយលក្ខណ៍អក្សរ៖[17] ភាគីប្តី ប្រពន្ធអាចរៀបចំកិច្ចព្រមព្រៀងលែងគ្នាជាមុន ហើយភ្ជាប់ទៅជាមួយពេលយកពាក្យសុំទៅដាក់នៅតុលាការ។ ជាទូទៅកិច្ចព្រមព្រៀងនេះ ភាគច្រើនសរសេរនូវខ្លឹមសារចម្បង គឺឆន្ទៈនៃការព្រមព្រៀងលែងលះ និងជាយថាហេតុ ការបែងចែកសិទ្ធិអំណាចមេបាលើកូនបន្ទុកចំណាយដើម្បីចិញ្ចឹមថែរក្សាកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ការបែងចែកទ្រព្យសម្បត្តិរួម និងការនាំយកពាក្យសុំទៅដាក់នៅតុលាការមានសមត្ថកិច្ច ដើម្បីទទួលបានដីកាសម្រេចជាអាទិ៍។

ទម្រង់ដោយផ្ទាល់មាត់៖ [18] ទម្រង់នេះភាគច្រើនគេប្រើប្រាស់ដោយប្រជាជន ដែលមិនសូវយល់ដឹងពីច្បាប់ និងមិនមានលទ្ធភាពពឹងពាក់មេធាវី។ តាមរយៈទម្រង់នេះ នៅពេលប្តីប្រពន្ធសម្រេចថាលែងលះគ្នា

[16] មាត្រា ៤ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង តារាងឧបសម្ព័ន្ធ)

[17] អត្ថបទរៀបរៀងដោយលោក ផុន វណ្ណា សមាជិកស្ថាបនិកសាមាគមសាលាត្រាជូ (លក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង)

[18] អត្ថបទរៀបរៀងដោយលោក ផុន វណ្ណា សមាជិកស្ថាបនិកសាមាគមសាលាត្រាជូ (លក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង)

ហើយពួកគាត់នាំគ្នាទៅតុលាការ ដើម្បីធ្វើសេចក្តីថ្លែងការណ៍អំពីឆន្ទៈ នៃការព្រមព្រៀងលែងលះរបស់ខ្លួន នៅចំពោះមុខក្រឡាបញ្ជី ដែលទទួលពាក្យសុំនោះ តំណាលគ្នានឹងពាក្យសុំ។

តាមទ្រឹស្តីពិតរបស់ច្បាប់ ឆន្ទៈនៃការព្រមព្រៀងរបស់ប្តី ប្រពន្ធ គឺជារឿងដ៏សំខាន់បំផុតដែលចៅក្រមត្រូវការវែកញែក និងស្រាវជ្រាវដើម្បីទទួលស្គាល់ ថាតើការព្រមព្រៀងនោះ បានការពារផលប្រយោជន៍រៀងៗខ្លួនរបស់ភាគីដោយយុត្តិធម៌ ឬទៅ? ពីព្រោះនៅក្នុងសង្គមខ្មែរនាបច្ចុប្បន្ន អំពើហិង្សាក្នុងគ្រួសារតែងតែកើតឡើងជាញឹកញាប់។

### ២.១.១.២ ពាក្យសុំលែងលះ

នៅក្នុងពាក្យសុំលែងលះដោយការព្រមព្រៀងរបស់សហព័ទ្ធ ដែលមានគោលបំណងចង់ដាក់ពាក្យសុំលែងលះ អាចដាក់ពាក្យទៅតុលាការ ប៉ុន្តែត្រូវបំពេញទម្រង់បែបបទនៃការដាក់ពាក្យសុំ ទៅតាមបញ្ញត្តិច្បាប់ដែលបានកំណត់។[19]

### ២.១.១.៣ ពាក្យសុំជាលាយលក្ខណ៍អក្សរ

ពាក្យសុំលែងលះត្រូវធ្វើឡើងដោយអ្នកដាក់ពាក្យសុំផ្ទាល់ ឬតាមរយៈអ្នកតំណាងដោយអាណត្តិរបស់ខ្លួនក៏បាន។ មួយវិញទៀត អ្នកដាក់ពាក្យសុំ ឬអ្នកតំណាងដោយអាណត្តិ ត្រូវរៀបចំលិខិតពាក្យសុំមុននឹងដាក់ទៅតុលាការ ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម ៖[20]

- **ឈ្មោះ និង អាសយដ្ឋាន របស់អ្នកដាក់ពាក្យសុំ៖** ប្តី ឬប្រពន្ធ ដែលបានយកពាក្យមកដាក់ត្រូវសរសេរឈ្មោះ ភេទ អាយុ សញ្ជាតិ និង សរសេរអាសយដ្ឋាន (ផ្ទះលេខ....ផ្លូវ....ក្រុម.....ភូមិ....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ......ខេត្ត/រាជធានី...... នៅក្នុងពាក្យសុំ។ ប្រសិនបើមានអ្នកតំណាងដោយអាណត្តិដែលច្បាប់បានកំណត់ត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះ នៅក្នុងពាក្យសុំផងដែរ។
- **ខ្លឹមសារ នៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ៖** ជាការសរសេរនូវអ្វីដែលអ្នកដាក់ពាក្យសុំទាមទារ ហើយនឹងបញ្ជាក់ពីទំហំនៃរឿងក្តីដែលត្រូវឱ្យតុលាការលើកយកមកវិនិច្ឆ័យ និងសម្រេចសេចក្តីផងដែរ។ សម្រាប់ខ្លឹមសារទាក់ទងនឹងការសរសេរពាក្យសុំលែងលះ ដោយការព្រមព្រៀង ចំណុចនេះត្រូវសរសេរឱ្យបានជាក់លាក់ ដើម្បីស្នើឱ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំ ដែលអ្នកដាក់ពាក្យសុំលែងលះជាមួយភាគីម្ខាងទៀត និងជាការទាមទារផ្សេងៗទៀត ដូចជាការបែកចែកសិទ្ធិ

[19] មាត្រា ២៦ កថាខណ្ឌទី១ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង២០១០)
[20] មាត្រា ២៦ កថាខណ្ឌទី២ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង២០១០)

អំណាចមេបាលើកូន ការអាចចូលជួបប្រាស្រ័យទាក់ទងជាមួយកូន របស់អ្នកដែលមិនមានសិទ្ធិអំណាចមេបា ការទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិ (ការទាមទារបន្ទាប់បន្សំ) ជាដើម។

- **អង្គហេតុជាមូលហេតុនៃការទាមទារៈ** នៅក្នុងរឿងក្ដីលែងលះដោយការព្រមព្រៀង មូលដ្ឋានគតិយុត្តនៃការទាមទារ ដើម្បីលែងលះបាន គឺអង្គហេតុនៃការកើតឡើងនៃចំណងអាពាហ៍ពិពាហ៍ ដែលបានបញ្ជាក់តាមសំបុត្រអាពាហ៍ពិពាហ៍ និងអង្គហេតុនៃការសម្ដែងឆន្ទៈនៃការព្រមព្រៀងលែងលះគ្នា ដែលបញ្ជាក់ដោយកិច្ចព្រមព្រៀង ឬការអះអាងរបស់ភាគី។ ម៉្យាងទៀត ការចាត់ចែងអំណាចមេបាលើកូន ក៏ជាអង្គហេតុដែលអាចទាមទារឲ្យតុលាការសម្រេចចាត់ចែងចំពោះកូនផងដែរ។ លើសពីនេះទៀត គឺជាអង្គហេតុដែលអាចទាមទារឲ្យមានការចាត់ចែងទ្រព្យសម្បត្តិ សំដៅលើអង្គហេតុដែលបញ្ជាក់ពីការមានទ្រព្យសម្បត្តិរួមគ្នា(ទ្រព្យសកម្ម និងទ្រព្យអកម្ម) ដែលអង្គហេតុបញ្ជាក់ដោយឯកសារនានា ដូចជាប័ណ្ណសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ ឬលិខិតសម្គាល់ម្ចាស់យានយន្តជាអាទិ៍។

### ២.១.១.៤ ពាក្យសុំដោយផ្ទាល់មាត់

ក្នុងករណីដែលភាគីណាម្ខាងនៃអ្នកដាក់ពាក្យសុំ ដែលមានកិច្ចការចាំបាច់ណាមួយ ដែលមិនបានបំពេញទៅតាមលក្ខខណ្ឌទម្រង់ខាងលើ ដូចនេះពួកគាត់អាចធ្វើការដាក់ពាក្យសុំដោយផ្ទាល់មាត់ ដោយគ្រាន់តែអ្នកដាក់ពាក្យសុំត្រូវធ្វើតាមសេចក្ដីថ្លែងការណ៍នូវចំណុច ដែលបានរៀបរាប់ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជីដែលទទួលពាក្យសុំ ហើយក្រឡាបញ្ជី ត្រូវធ្វើការកត់ត្រាទុកនៅក្នុងកំណត់ហេតុ។ កំណត់ហេតុនោះត្រូវចាត់ទុកជាលិខិតនៃពាក្យសុំ។ ពេលដាក់ពាក្យសុំ បើអ្នកដាក់ពាក្យសុំមានភស្តុតាង ឯកសារដូចជាសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ សំបុត្របញ្ជាក់កំណើតកូន ឬឯកសារនានាដែលបញ្ជាក់ពីទ្រព្យសម្បត្តិជាដើម គាត់ត្រូវដាក់ជូនតុលាការនូវឯកសារច្បាប់ដើម ឬឯកសារដែលមានសេចក្ដីបញ្ជាក់ដើម្បីឱ្យតុលាការងាយស្រួលក្នុងការពិនិត្យ និងឆាប់ទទួលស្គាល់អង្គហេតុ។[21]

### ២.១.១.៥ សមត្ថកិច្ចដោះស្រាយ

#### ក. ក្រុមប្រឹក្សាឃុំ-សង្កាត់

ការដាក់ពាក្យសុំលែងលះទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ជាជម្រើសរបស់គូរភាគី ពោលគឺសហព័ទ្ធអាចដាក់ពាក្យសុំទៅតុលាការមានសមត្ថកិច្ចដោយផ្ទាល់ក៏បាន។ ប្រសិនបើភាគីណាម្ខាងបានសម្រេចដាក់ពាក្យសុំទៅក្រុមប្រឹក្សាឃុំ-សង្កាត់នាលំនៅឋានប្ដី ឬប្រពន្ធ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវមានសមត្ថកិច្ចបឋម គឺជាអ្នក

[21] មាត្រា ២៦ កថាខណ្ឌទី៣ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង២០១០)

ផ្សះផ្សាគូភាគីជាមុនសិន។ ក្នុងដំណាក់កាលនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ពុំមានសមត្ថកិច្ច ក្នុងការធ្វើសេចក្តីសម្រេចថាឱ្យគូភាគីលែងលះគ្នា ការបែងចែកទ្រព្យសម្បត្តិ កំណត់អ្នកមានអំណាចមេបាលើកូន និងការបង់អាហារកាតព្វកិច្ចឡើយ។ គោលបំណងនៃការផ្សះផ្សា គឺដើម្បីឱ្យបុគ្គលទាំងពីរត្រូវគ្នា ឬសះជាគ្នាវិញ ដើម្បីបន្តការរស់នៅក្នុងជីវភាពជាប្តីប្រពន្ធសារជាថ្មី ដូចនេះហើយក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែខិតខំធ្វើយ៉ាងណាបញ្ចុះបញ្ចូលគូភាគីឱ្យសះជាក្នុងអំឡុងពេល ១៥ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ។ នៅពេលដែលគូភាគីត្រូវគ្នាវិញហើយ ក្រោយពីមានការផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើកំណត់ហេតុអំពីអ្វីដែលគូភាគីបានសះជានឹងគ្នា និងធ្វើលិខិតកិច្ចសន្យាឱ្យគូភាគីទាំងពីរ ទទួលយកពីការផ្សះផ្សានេះ។ ប៉ុន្តែប្រសិនបើ ការខិតខំផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ពុំសម្រេចទេ ហើយគូភាគីនៅតែទទូចចង់ធ្វើការលែងលះ និងគ្មានសង្ឃឹមថាអាចសះជាគ្នាទេ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យសុំទៅតុលាការ ដើម្បីឱ្យតុលាការធ្វើចំណាត់ការបន្ត។[22]

### ខ. សាលាដំបូងរាជធានី-ខេត្ត

បន្ទាប់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើការផ្សះផ្សាមិនបានសម្រេច ហើយពាក្យសុំត្រូវបញ្ជូនទៅឱ្យតុលាការនៅលំនៅឋានរបស់ប្តី ឬប្រពន្ធ ដូច្នេះតុលាការនឹងបន្តចំណាត់ការនេះ ព្រោះមានតែតុលាការទេ ដែលមានសមត្ថកិច្ចសម្រេចឱ្យគូភាគីលែងលះគ្នា ឬមិនអាចលែងលះគ្នាបានដោយការចេញដីកាសម្រេច មុននឹងឈានដល់ដំណើរការនីតិវិធីជំនុំជម្រះដោយចៅក្រម ពាក្យសុំត្រូវឆ្លងកាត់ការពិនិត្យជាមុនសិន។[23]

- **ការពិនិត្យពាក្យសុំ៖** នៅពេលដែលពាក្យសុំបានដាក់ជូនទៅតុលាការ អ្នកដែលមានសមត្ថកិច្ចទទួលពាក្យសុំ គឺមន្ត្រីរដ្ឋបាល ដែលទទួលបន្ទុកនៅការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិកប្រចាំការនៅតុលាការ។ បន្ទាប់មកពាក្យសុំត្រូវបញ្ជូនទៅក្រឡាបញ្ជី ហើយក្រឡាបញ្ជីត្រូវពិនិត្យ និងចុះលេខលើសំណុំរឿងដែលទទួលបាននោះ ប្រសិនបើពិនិត្យឃើញថាពាក្យសុំមិនត្រឹមត្រូវតាមទម្រង់ដែលច្បាប់បានកំណត់ទេនោះ ត្រូវរាយការណ៍ជូនចៅក្រមដើម្បីឱ្យចៅក្រមសម្រេច ថាត្រូវបង្គាប់ឱ្យកែតម្រូវ ឬលើកពាក្យសុំចោល។ ផ្ទុយមកវិញ បើពិនិត្យឃើញថាពាក្យសុំត្រឹមត្រូវសព្វគ្រប់តាមទម្រង់ហើយ ក្រឡាបញ្ជីត្រូវបញ្ជូនពាក្យសុំនោះទៅចៅក្រមដើម្បីសម្រេចបើកការជំនុំជម្រះ។ នៅក្នុងការដាក់ពាក្យ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធលើពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់ ) រៀល។[24] ឯប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។[25]

---

[22] មាត្រា ៤២ (ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ)

[23] មាត្រា ៤៣ (ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ)

[24] មាត្រា ២២ កថាខណ្ឌទី១ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង២០១០)

[25] មាត្រា ៦៤ (ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦)

- **ការកោះហៅគូភាគី៖** ក្រោយពីពិនិត្យពាក្យសុំឃើញថាត្រឹមត្រូវអស់ហើយតុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទកោះហៅគូភាគីឱ្យចូលមកតុលាការ ដើម្បីដំណើរការនីតិវិធីរឿងក្តីលែងលះ ដោយភាគីមានប្រសិនបើភាគី មិនព្រមចូលខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី មួយលាន រៀលបាន។[26] ការកោះហៅ គឺដើម្បីឱ្យអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀតអះអាងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ឬដើម្បីប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀត ហើយតុលាការក៏អាចកោះហៅបានបើយល់ឃើញថាចាំបាច់ ដោយកំណត់កាលបរិច្ឆេទ។ នៅកាលបរិច្ឆេទឱ្យអ្នកដាក់ពាក្យសុំ ឬភាគីអះអាងសាមីខ្លួនអាចពឹងអ្នកតំណាងដោយអាណត្តិរបស់ខ្លួនបង្ហាញជំនួសបាន ដោយពុំចាំបាច់បង្ហាញខ្លួនចំពោះមុខតុលាការផ្ទាល់ក៏បាន ប៉ុន្តែចំពោះកាលបរិច្ឆេទប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់ឱ្យសាមីដែលកោះហៅ ត្រូវបង្ហាញខ្លួនមកតុលាការ និងពន្យល់តុលាការពីកាលៈទេសៈដោយផ្ទាល់ ដើម្បីឱ្យតុលាការក្តាបអង្គហេតុពិតនៃរឿងក្តី។[27]
- **ការផ្សះផ្សានៅតុលាការ** ប្រសិនបើគូភាគីនៅតែទទូចសុំលែងលះ តុលាការប្រជាជនខេត្ត-ក្រុងត្រូវអញ្ជើញប្តី ប្រពន្ធ ឱ្យចូលមកកាន់តុលាការជាប្រញាប់ ដើម្បីធ្វើការផ្សះផ្សា។[28] ទោះបីការសម្តែងឆន្ទៈរបស់គូភាគីក៏ដោយ ក៏តុលាការព្យាយាមធ្វើការផ្សះផ្សាភាគីឱ្យត្រូវគ្នាវិញប្រសិនបើចៅក្រមយល់ឃើញថាការលែងលះនោះអាចបង្កផលប៉ះពាល់ខ្លាំងដល់កូន។ ការផ្សះផ្សានេះ គឺដើម្បីឱ្យភាគីសះជាគ្នាវិញដោយលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារទេ តែគឺដើម្បីឱ្យភាគីដកពាក្យសុំលែងលះទៅវិញ ហើយរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធវិញ។ ប៉ុន្តែប្រសិនបើការផ្សះផ្សាម្តងហើយម្តងទៀតក្នុងដំណាក់កាលនីមួយៗនៅតែមិនបានសម្រេចទេនោះ ចៅក្រមនឹងបន្តសម្រេចសេចក្តីតាមឆន្ទៈរបស់គូភាគីនៃអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ឬជនផ្សេងទៀតនោះ។
- **ការទាញហេតុផលដោយផ្ទាល់មាត់ និងការសាកសួរដោយឆន្ទានុសិទ្ធិ** ក្នុងដំណើរនៃនីតិវិធីនៃរឿងក្តីលែងលះដោយមានការព្រមព្រៀង តុលាការអាចធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ ឬមិនធ្វើបានដោយឆន្ទានុសិទ្ធិតាមការយល់ឃើញថាចាំបាច់ ឬមិនចាំបាច់ប៉ុន្តែមិនធ្វើជាសាធារណៈនោះឡើយ។[29]

---

[26] មាត្រា ២៩ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង២០១០)
[27] មាត្រា ១៥ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង២០១០)
[28] មាត្រា ៤៥ ដល់ មាត្រា៥៣ (ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ)
[29] មាត្រា ១៦ (ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង២០១០)

ជាគោលការណ៍ការធ្វើនីតិវិធីទាញហេតុផលមាត់ត្រូវធ្វើនៅសវនាការ ចំណែកឯនីតិវិធីនៃការសាកសួរអាចធ្វើឡើងក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់ចៅក្រម។ នីតិវិធីនៃការសាកសួរ ក្រៅពីការផ្តល់វេទិកាឱ្យភាគីបញ្ជាក់ឱ្យកាន់តែច្បាស់ អំពីឆន្ទៈព្រមព្រៀងរបស់ខ្លួនលើការទាមទារ ហើយតុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឬពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិទៀតផង។[30] នៅក្នុងការដឹកនាំនីតិវិធីតុលាការអាចលើកយកអង្គហេតុដែលភាគីមិនបានអះអាងមកធ្វើជាមូលដ្ឋាន នៃដីកាសម្រេចបាន។

**២.១.១.៦ ការចេញដីកាសម្រេច**

ក្នុងការលែងលះដោយការព្រមព្រៀង ការសម្រេចសេចក្តីត្រូវចេញដីកាសម្រេច ដើម្បីចេញដីកាសម្រេចតុលាការពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ព្រោះរឿងក្តីបែបនេះជារឿងក្តីមិនស្មុគស្មាញ គ្មានចំណុចវិវាទ ដោយសារភាគីបានព្រមព្រៀងគ្នា ហើយការលែងលះ វាជាការសម្ងាត់របស់ភាគីដូចនេះដើម្បីចេញដីកាសម្រេចឱ្យលែងលះតាមការព្រមព្រៀង គឺមិនចាំបាច់ត្រូវទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈឡើយ។ ដីកាសម្រេចឱ្យលែងលះតាមការព្រមព្រៀង ជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងជាគោលការណ៍ធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនោះ។[31]

ក្នុងសេចក្តីសម្រេច ចៅក្រមត្រូវយោងទៅលើមូលដ្ឋានជាច្រើនក្នុងការសម្រេច ចំណុចដំបូងចៅក្រមត្រូវពិចារណាទៅលើស្ថានភាពគតិយុត្ត នៃទំនាក់ទំនងរវាងប្តី និងប្រពន្ធ នៃការលែងលះថាតើចំណងអាពាហ៍ពិពាហ៍របស់គាត់ត្រឹមត្រូវស្របតាមច្បាប់ មានការទទួលស្គាល់ដោយច្បាប់ ដែល ឬអត់។ បន្ទាប់មកចៅក្រមពិចារណាលើឆន្ទៈពិតក្នុងការលែងលះ ប្រសិនបើចៅក្រមស្វែងរកឃើញថា ភាគីណាម្ខាងមិនមានឆន្ទៈព្រមព្រៀងពិតប្រាកដក្នុងការលែងលះទេ ចៅក្រមនឹងចេញដីកាសម្រេចលើកពាក្យសុំចោល ដើម្បីបញ្ចប់នីតិវិធីលែងលះ។[32] ចៅក្រមក៏ធ្វើការពិចារណាទៅលើចំណុចនៃការទាមទារចម្បងរបស់ភាគី នៃការលែងលះ ព្រមទាំងចំណុចបន្ទាប់បន្សំផ្សេងទៀតដូចជា ការបែងចែកអ្នកមានសិទ្ធិអំណាចមេបាលើកូន ការចូលជួបប្រាស្រ័យទាក់ទងជាមួយកូនរបស់អ្នកមិនមានសិទ្ធិអំណាចមេបា ការទទួលបន្ទុកសោហ៊ុយចំណាយដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ឬការបែងចែកទ្រព្យសម្បត្តិ បំណុលជាដើម។

ដីកាសម្រេចលើពាក្យសុំលែងលះដោយមានការព្រមព្រៀងរបស់ភាគី ជាដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលត្រូវធ្វើការជូនដំណឹងតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារ

---

[30] មាត្រា ២៧ (ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០)

[31] មាត្រា ៣៥ (ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០)

[32] មាត្រា ៣៩ (ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០)

ចម្លងយថាភូតនៃដីកាសម្រេច ទៅភាគីនៃការលែងលះដែលជាសាមីខ្លួនក្នុងរឿងលែងលះនេះតែម្តង។[33] ការជូនដំណឹង មិនចាំបាច់ត្រូវធ្វើដោយក្រឡាបញ្ជីជាអ្នកបញ្ជូនដោយផ្ទាល់ទេ គឺអាចធ្វើឡើងតាមរយៈការផ្ញើតាមប្រៃសណីយ៍ក៏បាន។ ដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀងក៏ដូចជា ដីកាសម្រេចលើអង្គសេចក្តីដែលមិនមែនជាបណ្តឹងមានលក្ខណៈខុសគ្នានឹងដីកាសម្រេចនៅក្នុងបណ្តឹងរដ្ឋប្បវេណី ត្រង់ថាដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីដែលមិនមែនជាបណ្តឹងមានអានុភាពចូលជាស្ថាពរ មិនមែនដោយការជូនដំណឹងទេ គឺថាដីកាសម្រេចលើពាក្យសុំលែងលះតាមការព្រមព្រៀង ក៏ដូចជាដីកាសម្រេចលើអង្គសេចក្តីនៃរឿងក្តីដែលមិនមែនជាបណ្តឹង ត្រូវបានចូលជាស្ថាពរមានអានុភាពអនុវត្តនៅពេលផុតរយៈពេលប្តឹងជំទាស់មានរយៈពេល ០២ សប្តាហ៍ គិតចាប់ពីបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ។[34]

## ២.២ នីតិវិធីនៃការលែងលះ ក្នុងករណីមានពាក្យបណ្តឹងលែងលះ

### ២.២.១ តុលាការមានសមត្ថកិច្ច

ការកំណត់ពីតុលាការដែលមានសមត្ថកិច្ច នៅក្នុងរឿងក្តីលែងលះ ត្រូវអនុលោមយកតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលបានចែងថា៖ បណ្តឹងលែងលះគ្នា និងបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព(ភាពមាន) ឬនត្ថិភាព(ភាពគ្មាន)នៃបុត្តភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់ សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃ ទំនាក់ទំនងឋានៈបុគ្គល ដែលពាក់ព័ន្ធនឹងបណ្តឹងនោះ។[35]

ហេតុនេះ តុលាការមានសមត្ថកិច្ចក្នុងរឿងក្តីលែងលះ អាចជាតុលាការខាងលំនៅឋានរបសើដើមចោទក៏បាន ឬជាតុលាការខាងលំនៅឋានរបស់ចុងចម្លើយ ក៏បានដែរ ។

ឧទាហរណ៍ ៖ បុរស ក. និងនារី ខ. ជាប្តីប្រពន្ធនឹងគ្នា។ អ្នកទាំងពីរមានលំនៅឋានក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរយៈពេល ២ឆ្នាំកន្លងផុតទៅ បុរស ក. បានចុះចេញចោលពីផ្ទះទៅរស់នៅជាមួយឪពុកម្តាយរបស់គាត់នៅឯខេត្តពោធិ៍សាត់វិញ ក្រោយពីមានទំនាស់ជាមួយនឹងប្រពន្ធ។ ឧបមាថា នារី ខ. មានបំណងចង់ប្តឹងលែងលះ ដូច្នេះ នារី ខ. អាចដាក់ពាក្យបណ្តឹងលែងលះ នៅសាលាដំបូងរាជធានីភ្នំពេញក៏បាន ឬ នៅសាលាដំបូងខេត្តពោធិ៍សាត់ក៏បានដែរ។

### ២.២.២ បណ្តឹងលែងលះ

ពាក្យបណ្តឹងលែងលះត្រូវធ្វើជាលាយល័ក្ខណ៍អក្សរហើយ ត្រូវសរសេរនូវចំណុចខាងក្រោមនេះ៖[36]

---

[33] មាត្រា ៣៦ (ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០)

[34] មាត្រា ៤០ (ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០)

[35] មាត្រា ១០ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧) និងមាត្រា ៥ (ច្បាប់ស្តីពី នីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)

[36] មាត្រា ៧៥ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

- ឈ្មោះ និង អាសយដ្ឋានរបស់ភាគី និង ឈ្មោះអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់កំណត់។
- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ ដើម្បីបញ្ជាក់ការទាមទារ។

សម្រាប់ការដាក់ពាក្យបណ្តឹងខាងលើនេះ ដើមចោទត្រូវបង់ពន្ធដាក់ ពាក្យបណ្តឹងចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល។

**២.២.៣ ការផ្សះផ្សារដោយតុលាការ**

ចំពោះនីតិវិធីនៅក្នុងតុលាការមានលក្ខណៈដូចគ្នា មិនថាតុលាការទទួលពាក្យបណ្តឹងដោយផ្ទាល់ពីភាគីដើមចោទ ឬតុលាការទទួលពាក្យបណ្តឹងពីមេឃុំ ចៅសង្កាត់ទេ ក្រោយទទួលពាក្យបណ្តឹងតុលាការត្រូវចាត់តាំងចៅក្រមមួយរូបដើម្បីធ្វើការផ្សះផ្សារ។ ទោះបីជាសហព័ទ្ធម្ខាងណា ទាមទារលែងលះខ្លាំងយ៉ាងណា ក៏តុលាការអាចធ្វើការផ្សះផ្សារដោយឆន្ទានុសិទ្ធិ។ ការផ្សះផ្សារ គឺមិនមែនធ្វើឱ្យភាគីសះជាគ្នាដោយលះបង់ការទាមទារ ឬទទួលស្គាល់ការទាមទារនោះទេ គឺផ្សះផ្សារដើម្បីឱ្យមានការដកពាក្យបណ្តឹងលែងលះវិញ ហើយរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធដូចដើម។[37]

**២.២.៤ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី ដើម្បីបំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគី មិនយល់ស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តី នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យកាន់តែគ្រប់ជ្រុងជ្រោយល្អិតល្អន់។[38]

ជាគោលការណ៍ គូភាគីជាអ្នកស្នើសុំឱ្យតុលាការពិនិត្យភស្តុតាង និយាយបានម៉្យាងទៀតថា គូភាគីជាអ្នកស្វះស្វែងរកភស្តុតាងផ្សេងៗមកដាក់ជូនតុលាការពិនិត្យដើម្បីជាផលប្រយោជន៍របស់ខ្លួន។ ស្របគ្នានេះដែរ តុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ហើយជាពិសេសតុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយគូភាគី មកធ្វើជាមូលដ្ឋាននៃសាលក្រមបាន។[39]

**២.២.៥ ការទាញហេតុផលដោយផ្ទាល់មាត់**

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តី ដែលក្នុងនោះសកម្មភាពរបស់តុលាការ និងសកម្មភាពរបស់ភាគីចំពោះការជម្រះក្តីនោះ ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយ

---

[37] មាត្រា ៩៨៧ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[38] មាត្រា ១០៣ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[39] មាត្រា ១៤ (ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)

ផ្ទាល់មាត់ ការស្តាប់សេចក្តីថ្លែងការណ៍នោះ នូវសាលសវនាការជាអសាធារណៈ នៅកាលបរិច្ឆេទដែលភាគីទាំងសងខាង អាចមានវត្តមានបាន។[40]

### ២.២.៦ សេចក្តីសម្រេចក្នុងរឿងលែងលះ

ក្រោយពីធ្វើការវិនិច្ឆ័យរួចហើយ តុលាការនឹងធ្វើការសម្រេចសេចក្តីដោយចេញជា សាលក្រម។ តាមធម្មតា សាលក្រមដែលសម្រេចអំពីការលែងលះ ត្រូវបញ្ជូនទៅឱ្យគូភាគីក្នុងអំឡុងពេល ២សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រម។[41] គូភាគីអាចប្តឹងឧទ្ធរណ៍នឹងសាលក្រម នេះបានក្នុងអំឡុងពេល ១ ខែ គិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម។ [42] សម្រាប់រឿងក្តីនេះ គឺតុលាការមិនអាចធ្វើការចេញសាលក្រមកំបាំងមុខឡើយ ពោលគឺ សាលក្រមដែលចេញដោយតុលាការ គឺជាសាលក្រមធម្មតា ដែលមិនអាចអនុញ្ញាតឱ្យមានការប្តឹងទាស់បានទេ។[43]

### ២.២.៧ ការចាត់ចែងរក្សាការពារ

តុលាការដែលបានទទួលពាក្យបណ្តឹងលែងលះគ្នា ក្នុងករណីចាំបាច់អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារចំពោះ ការបំបែកលំនៅឋាន ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និង សោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន។[44]

ផ្អែកតាមអត្ថន័យខាងលើនេះ ឃើញថា ការចាត់ចែងរក្សាការពារ គឺជាវិធានការដើម្បីធានាឱ្យជីវភាពរស់នៅក្នុងគ្រួសារអាចបន្តទៅទៀតបានដោយសមរម្យ បើទោះបីជាសហព័ន្ធទាំងសងខាង កំពុងតែប្តឹងទាមទារលែងលះគ្នាក៏ដោយ ។

ឧទាហរណ៍៖ វីណា និង ចាន់ណា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១៣ អ្នកទាំងពីរមានកូនចំនួន ២ នាក់ ឈ្មោះ សាណា និង ដារី។ នាពេលថ្មីៗកន្លងទៅនេះ អ្នកទាំងពីរមានវិវាទជាមួយគ្នាយ៉ាងខ្លាំង រហូតដល់មានការជេរបញ្ចោរគ្នាទៅវិញទៅមក ហើយ ចាន់ណា បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះយ៉ាងច្រើន។ ចាប់តាំងពីពេលនោះមក ក្រុមគ្រួសាររបស់អ្នកទាំងពីរមិនដែលមានសេចក្តីសុខនោះទេ គឺរមែងតែងតែឈ្លោះប្រកែកគ្នាឥតឈប់ឈរ។ នៅទីបំផុត ចាន់ណា បានចុះចេញពីផ្ទះ ទៅរស់នៅ

[40] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុន ភាគទី១ ទំព័រទី ៨៧ និង៨៨

[41] មាត្រា ១៩០ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[42] មាត្រា ២៦៤ (កថាខណ្ឌទី ១ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[43] មាត្រា ១៣ (កថាខណ្ឌទី ១ ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)

[44] តាមមាត្រា ៩៨៣ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

ទីកន្លែងផ្សេងៗ។ ក្រោយមក ចាន់ណា មានបំណងលែងលះពី រីណា ហើយទាមទារយកកូនទាំងពីរនាក់ទៅគ្រប់គ្រង ដោយមូលហេតុថា រីណា មិនមានលទ្ធភាពចិញ្ចឹមបីបាច់កូនទាំងពីរនាក់ឡើយ ពីព្រោះតែនាងមិនមានមុខរបរដើម្បីចិញ្ចឹមជីវិត។ ប្រឈមនឹងស្ថានភាពបែបនេះ រីណា អាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារដើម្បីស្នើរសុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ជាបណ្ដោះអាសន្ន (រហូតដល់តុលាការសម្រេចពីសិទ្ធិគ្រប់គ្រងកូន ឬកំណត់ពីអ្នកមានអំណាចមេបាលើកូនជាស្ថាពរ) ស្នើរសុំឱ្យតុលាការសម្រេចបង្គាប់ឱ្យ ចាន់ណា បង់ប្រាក់ (ឧទាហរណ៍ ចំនួន ៦០ ម៉ឺនរៀល ក្នុងមួយខែ) ដើម្បីចិញ្ចឹមកូនទាំងពីរនាក់ជាបណ្ដោះអាសន្ន (រហូតដល់ពេលដែលតុលាការសម្រេចសេចក្ដីជាស្ថាពរ) ជាដើម។

# ជំពូកទី៣
# សិទ្ធិ និងកាតព្វកិច្ច
# ក្រោយពេលលែងលះ

# ជំពូកទី៣

# សិទ្ធិ និងភាតព្វកិច្ចក្រោយពេលលែងលះ

## ៣.១ សញ្ញាណទូទៅ អានុភាពនៃការលែងលះ

ការលែងលះមានអានុភាពផ្តាច់ចំណងអាពាហ៍ពិពាហ៍ រវាងសហព័ទ្ធនៅពេលដែលសេចក្តីសម្រេចអំពីការលែងលះចូលជាស្ថាពរ។ សេចក្តីសម្រេចអំពីការលែងលះនឹងចូលជាស្ថាពរ នៅអំឡុងពេល នៃបណ្តឹងឧបាស្រ័យបានកន្លងផុត។ បើសេចក្តីសម្រេចនេះជាសាលក្រម អំឡុងពេលប្តឹងឧទ្ធរណ៍ ១ខែកន្លងផុត ដោយគិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រម។[45] ក្នុងករណីដែលសេចក្តីសម្រេចនេះជា ដីកាស្រេច គឺត្រូវប្តឹងជំទាស់ក្នុងអំឡុងពេល ២សប្តាហ៍ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹង ពីដីកាសម្រេចនោះ។[46] ដូច្នេះនៅពេលដែលផុតអំឡុងពេលដូចបានបញ្ជាក់ជូនខាងលើ សេចក្តីសម្រេចអំពីការលែងលះនឹងចូលជាស្ថាពរ។

### ៣.១.១ និយមន័យ អានុភាពនៃការលែងលះ

- ក្នុងន័យច្បាប់ពាក្យ អានុភាព ជាជនគតិយុត្ត ដែលកើតចេញពីលិខិតគតិយុត្តដូចជា កិច្ចសន្យា ច្បាប់ សេចក្តីសម្រេចរបស់តុលាការ សេចក្តីសម្រេចរបស់រដ្ឋបាល។ល។
  ឧទាហរណ៍៖ តុលាការបានចេញសាលក្រម ស្តីពីការលែងលះរវាង ក និង ខ ដែលមានអានុភាព ក្នុងការអនុវត្តលើការចាត់ចែងទ្រព្យសម្បត្តិ ការចាត់ចែងលើអំណាចមេបា និងលក្ខខ័ណ្ឌផ្សេងៗទៀត។
- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត បានពន្យល់ពាក្យ « អានុភាព » មានន័យថាជាសេចក្តីប្រាកដក្នុងចិត្ត ការចូលចិត្តស៊ប់ , ជំនឿស៊ប់ , សេចក្តីដឹងច្បាស់។
  ឧទាហរណ៍៖ មានអានុភាព ក្នុងការសម្រេចធ្វើអ្វីមួយយ៉ាងម៉ត់មាំ។
- ចំណែកឯ « អានុភាព » មានន័យថា អំណាច , តេជះ , សេចក្តី អង់អាច , សេចក្តីក្លាហាន។
  ឧទាហរណ៍៖ មនុស្សមានអានុភាព ខ្លាំងក្លា ដើម្បីប្រយុទ្ធរាល់ឧបសគ្គ។

## ៣.២. អានុភាពនៃការលែងលះ ចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់សហព័ទ្ធ

ការលែងលះនាំឱ្យសហព័ទ្ធរួចផុតពីកាតព្វកិច្ចទាំងឡាយ ដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ ការទាមទារអាហារកិច្ចពីសហព័ទ្ធម្ខាងទៀត លុះត្រាមានលក្ខខណ្ឌសមស្របតាមខ្លឹមសារដូចខាងក្រោម៖[47]

[45] មាត្រា ២៦៤ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[46] មាត្រា ៥០ (កថាខណ្ឌទី ១ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)

[47] មាត្រា ៧៦ និងមាត្រា ៧៧ (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មិនត្រូវបាននិរាករណ៍ដោយក្រមរដ្ឋប្បវេណីទេ)

- អតីតសហព័ទ្ធដែលស្នើសុំនោះ គ្មានកំហុសក្នុងការលែងលះគ្នា។
- អតីតសហព័ទ្ធមានការខ្វះខាត បានសេចក្តីថា ភាគីដែលគ្មានកំហុសពុំមានទ្រព្យសម្បត្តិ ឬមុខរបរជាក់លាក់សម្រាប់ចិញ្ចឹមជីវិតខ្លួន។ គួរកត់សម្គាល់ថាការខ្វះខាតនេះ មិនសំដៅតែទៅលើការខ្វះខាតនូវម្ហូបអាហារសម្រាប់បរិភោគប៉ុណ្ណោះទេ គឺថែមទាំងសំដៅលើអ្វីដែលជាធាតុចាំបាច់ សម្រាប់ឱ្យជនដែលមានសិទ្ធិទទួលអាហារកិច្ច អាចរស់នៅដោយសមស្រប ដូចជាអាចមានជម្រក សម្លៀកបំពាក់ លទ្ធភាពទិញថ្នាំសង្កូវ ជាដើម។[48]

ជាធម្មតា អតីតសហព័ទ្ធដែលត្រូវផ្តល់អាហារកិច្ច ត្រូវមានលទ្ធភាពផ្តល់អាហារកិច្ចនោះ។ ករណីនេះចៅក្រមពិនិត្យទៅលើប្រាក់បៀវត្ស លទ្ធភាពនៃការរកប្រាក់ចំណូល អាយុ សុខភាពរបស់ជននោះ ដើម្បីកំណត់ពីកម្រិតនៃអាហារកិច្ចដែលត្រូវបង់។ ក៏ប៉ុន្តែ ប្រសិនបើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះលែងមានសិទ្ធិទទួលអាហារកិច្ចទៀតហើយ។

ជាងនេះទៅទៀត ក្នុងករណី ប្តី ឬប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅមុនពេលលែងលះគ្នាក៏បាន។[49]

ឧទាហរណ៍ ៖ ព្រំ បញ្ញា បានរៀបការជាមួយនឹងនារីម្នាក់ឈ្មោះ ផាន់ បូផា។

ក្នុងករណីនេះ ផាន់ បូផា អាចប្រើនាមត្រកូលរបស់ប្តីនាងបាន ដោយប្តូរទៅជា ព្រំ បូផា វិញ។ ក្នុងករណីនេះ ប្រសិនបើអ្នកទាំងពីរលែងលះគ្នាវិញ បូផា អាចប្រើ ឈ្មោះ ព្រំ បូផា ដដែលក៏បាន ឬក៏ប្តូរទៅប្រើឈ្មោះ ផាន់ បូផា វិញក៏បានដែរ។

## ៣.៣ អានុភាពនៃការលែងលះ ចំពោះទ្រព្យសម្បត្តិ

### ៣.៣.១ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីនិងប្រពន្ធ ត្រូវបែងចែកដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់គូភាគី។[50] ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធអាចបែងចែកជា ៣ ប្រភេទ គឺទ្រព្យសម្បត្តិរួម ទ្រព្យសម្បត្តិដោយឡែករបស់ប្តី និងទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ។ ចំពោះទ្រព្យសម្បត្តិប្តីប្រពន្ធ បើសិនជានៅពេលរំលាយអាពាហ៍ពិពាហ៍ (លែងលះ) ប្តីប្រពន្ធឈានដល់ការព្រមព្រៀងបែងចែកទ្រព្យសម្បត្តិ តាមការពិភាក្សារបស់ប្តីប្រពន្ធ ដោយត្រូវបង្ហាញឱ្យច្បាស់អំពីទ្រព្យសម្បត្តិរួម ចំណែកនៃទ្រព្យសម្បត្តិដោយឡែក ទំហំ (រួមទាំងពេលធ្វើលទ្ធកម្ម ដើម

[48] មាត្រា ៧៦ (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

[49] មាត្រា ៩៨១ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[50] មាត្រា ៩៨០ កថាខណ្ឌទី១ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

ហេតុនៃការធ្វើលទ្ធកម្ម និងប្រវិត្ត ជាអាទិ៍) តម្លៃ ជាអាទិ៍ ហើយការព្រមព្រៀងនោះត្រូវបានគោរព។ សហព័ទ្ធនីមួយៗ ត្រូវទទួលបន្ទុកនូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងច្បាប់។[51]

### ៣.៣.២ ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ ត្រូវធ្វើតាមគោលការណ៍នៃការព្រមពៀងរបស់គូភាគី។[52] ផ្ទុយទៅវិញ បើពុំអាចពិភាក្សាគ្នាបានទេ គឺត្រូវតែធ្វើការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដោយផ្អែកទៅតាមចំណុចនីមួយៗដែលរួមមាន៖

- សហព័ទ្ធម្នាក់ៗត្រូវទទួលបាននូវទ្រព្យដោយឡែករបស់ខ្លួន។
- បន្ថែមពីលើទ្រព្យដោយឡែក សហព័ទ្ធម្នាក់ៗត្រូវទទួលបាន ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម។

ឧទាហរណ៍ ៖ ចេន និង សុភាព បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅឆ្នាំ២០០៥។ មុនពេលរៀបអាពាហ៍ពិពាហ៍ ចេន បានទិញរថយន្តមួយគ្រឿង ដើម្បីបម្រើជីវភាពគ្រួសារ ដោយទទួលបាននូវប្រាក់ចំណូលច្រើនគួរសម ចំណែកឯ សុភាព ជាប្រពន្ធវិញ ជាអ្នកធ្វើកិច្ចការផ្ទះ និងមើលថែទាំកូន។ តាមរយៈប្រាក់ចំណូលនេះ ចេន បានទិញដីក្នុងភូមិមួយកន្លែងនៅឆ្នាំ២០០៨។ នៅឆ្នាំ២០១៣ ចេន និង សុភាព បានលែងលះគ្នា។ ដូច្នេះ ចេន មានសិទ្ធិយករថយន្តដែលជាទ្រព្យសម្បត្តិដោយឡែករបស់គាត់បាន ចំណែកឯដីភូមិវិញ ដែលជាទ្រព្យសម្បត្តិរួម គឺត្រូវបែងចែកស្មើគ្នារវាង ចេន និង សុភាព។

ក៏ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទាររបស់ប្តី ឬប្រពន្ធណាម្ខាង តុលាការក៏អាចធ្វើការបែងចែកទ្រព្យសម្បត្តិរួម ដោយធ្វើការពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា៖ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅរបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍។[53]

ឧទាហរណ៍៖ កញ្ញា និង សារឿន គឺជាប្តីប្រពន្ធនឹងគ្នា ហើយបានសម្រេចចិត្តលែងលះគ្នានៅឆ្នាំ២០២២។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរមាន៖ ម៉ូតូមួយគ្រឿង(តម្លៃ ៣លានរៀល) ដែល សារឿន យកទៅប្រើប្រាស់ដើម្បីរត់ម៉ូតូឌុប មានគោមួយក្បាល (តម្លៃ ២លានរៀល) និងប្រាក់ចំនួន ៣លានរៀល។ អ្នកទាំងពីរមានកូនពីរនាក់ជាអនីតិជន (មិនទាន់មានអាយុគ្រប់ ១៨ឆ្នាំនៅឡើយ)។ ឧបមាថា អ្នកទាំងពីរបានព្រមព្រៀងគ្នាថាឱ្យ កញ្ញា ជាម្តាយជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ ក្រោយពេលលែងលះ។ នៅក្នុងករណីនេះ ដោយគិតអំពីផលប្រយោជន៍របស់កូន តុលាការអាចសម្រេចប្រគល់ម៉ូតូ

[51] មាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក)

[52] មាត្រា ៩៨០ (កថាខណ្ឌទី ១ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[53] មាត្រា ៩៨០ (កថាខណ្ឌទី ២ ចំណុច ខ. វាក្យខណ្ឌទី ២ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

តម្លៃប្រហែល ៣លានរៀល ឱ្យទៅសារឿន និងគោមួយក្បាលតម្លៃ ២លាន រៀល និងប្រាក់ ៣លានរៀល ឱ្យទៅ កញ្ញា ជាប្រពន្ធ។ ក្នុងសម្មតិកម្មនេះ ឃើញថា ទ្រព្យសម្បត្តិរួមត្រូវបែងចែកពាក់កណ្ដាលម្នាក់រវាងសហព័ទ្ធ។ ជាក់ស្ដែង ក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យធ្វើការបែងចែកបែបនេះ ដើម្បីជាផលប្រយោជន៍របស់កូន។

សូមធ្វើការកត់សម្គាល់ថា ការលែងលះអាចមានមូលហេតុបណ្ដាលមកពី ការប្រើអំពើហិង្សាផ្សេងៗ។ តាមច្បាប់ ការប្រើអំពើហិង្សារវាងប្ដីប្រពន្ធ គឺជាអំពើអនីត្យានុកូល ដែលឈានទៅដល់ការសម្រេចអំពីសំណង នៃការខូចខាតផងដែរ។ ក្នុងអត្ថន័យនេះ ការទាមទារលែងលះ និងការទាមទារអំពីសំណងនៃការខូចខាតដូច ខាងលើនេះ អាចធ្វើនៅក្នុងបណ្ដឹងតែមួយបាន។[54]

ផ្សេងពីនេះទៀត តុលាការក៏អាចសម្រេចឱ្យសហព័ទ្ធណាម្នាក់សងតម្លៃ នៃទ្រព្យសម្បត្តិដោយឡែក ដែលភាគីម្ខាងបានធ្វើការបំផ្លាញ ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ដែរ។

ឧទាហរណ៍ ៖ ឈ្មោះ ក. និង ឈ្មោះ ខ. ជាប្ដីប្រពន្ធ។ ឈ្មោះ ក. បានយកខ្សែដៃមានរបស់ឈ្មោះ ខ ជា ប្រពន្ធ (ខ្សែដៃដែលម្ដាយរបស់ឈ្មោះ ខ. បានធ្វើអំណោយឱ្យនាង) ទៅលក់ដើម្បីយកប្រាក់ទៅលេងល្បែង ដោយមិនឱ្យឈ្មោះ ខ. ដឹងឡើយ។ នៅពេលលែងលះ តុលាការអាចសម្រេចឱ្យឈ្មោះ ក. សងតម្លៃនៃខ្សែទៅ ឈ្មោះ ខ. វិញ ព្រោះថាខ្សែដៃនោះជាទ្រព្យដោយឡែករបស់ឈ្មោះ ខ. ។

## ៣.៤ អានុភាពនៃការលែងលះ ចំពោះកូន

### ៣.៤.១ ទស្សនទាននៃអាហារកាតព្វកិច្ច

ការរស់នៅក្នុងសង្គមតែងតែមានទំនាក់ទំនងគ្នា ទាំងនេះមានលក្ខណៈជាទំនាក់ទំនងញាតិ និងទំនាក់ ទំនងទ្រព្យ ហើយសម្រាប់ទំនាក់ទំនងញាតិដែលកំណត់ក្នុងច្បាប់ គឺទំនាក់ទំនងនេះមានអានុភាពចម្បងពីរគឺ ទី១ សន្តតិកម្ម និងទី២ ទំនាក់ទំនងឪពុកម្ដាយ និងកូន ដោយរាប់បញ្ចូលអាហារកាតពកិច្ច ជាអាទិ៍។

អាហារកាតព្វកិច្ច ជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្ដីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យ បុគ្គលម្នាក់ ឬច្រើននាក់ផ្ដល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅរបស់បុគ្គលផ្សេងទៀត ដែលមានទំនាក់ ទំនងញាតិនឹងគ្នា ដោយអាហារកាតព្វកិច្ចទាំងនេះមានបីទម្រង់ ទី១ អាហារកាតព្វកិច្ចរវាងញាតិ ទី២ អាហារ កាតព្វកិច្ចរវាងសហព័ទ្ធ[55] និង ទី៣អាហារកាតព្វកិច្ចរវាងឪពុក-ម្ដាយចំពោះកូនជាអនីតិជន។[56]

[54] មាត្រា ១១ (ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)
[55] មាត្រា ៩៦៦ និងមាត្រា ៩៧១ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)
[56] មាត្រា ១០៣៤ និងមាត្រា ១០៤០(ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

អាហារកាតព្វកិច្ច គឺជាជាអានុភាពនៃចំណងញាតិ ដែលសកម្មភាពនេះ គឺជាជំនួយផ្នែកហិរញ្ញវត្ថុចំពោះបុគ្គលដែលមិនអាចទ្រទ្រង់ជីវភាពបានដោយខ្លួនឯង ដែលយើងហៅថា ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច រីឯភាគីម្ខាងទៀត ហៅថា ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច។[57]

អាហារកាតព្វកិច្ច ដែលអាចក្លាយជាចំនួនទឹកប្រាក់នៃការទ្រទ្រង់ជីវភាព សម្រាប់បុគ្គលដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច គឺជាទឹកប្រាក់ដែលនៅសល់ បន្ទាប់ពីបុគ្គលមានករណីយកិច្ចត្រូវទទួលបន្ទុកអាហារកាតព្វកិច្ច បានចំណាយសម្រាប់ជីវភាពគ្រួសារ ប្រពន្ធ កូនចំណាយជាប្រចាំផ្ទាល់ខ្លួន ទៅតាមឋានៈក្នុងសង្គម ហើយចំនួនដែលនៅសល់នឹងក្លាយជាកម្មវត្ថុនៃអាហារកាតព្វកិច្ច។[58]

### ៣.៤.២ បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច

ជាគោលការណ៍ ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចគឺ ទី១ ញាតិដែលរស់នៅជាមួយគ្នា ទី២ ញាតិលោហិតខ្សែផ្ទាល់ និងទី៣ បងប្អូនបង្កើត ហើយក្រៅពីអ្នកទាំងនោះ តុលាការអាចឱ្យញាតិនៅក្នុងថ្នាក់ទី៣ ទទួលបន្ទុកករណីយកិច្ចអាហារកាតព្វកិច្ចប្រសិនបើមានស្ថានភាពពិសេស។ ក្នុងស្ថានភាពពិសេស គឺករណីដែលគ្មានញាតិ ដូចមានកំណត់ខាងលើ ឬមានញាតិដែលមានកំណត់ខាងលើ ប៉ុន្តែមិនអាចផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន ឬ ប្រសិនបើផ្គត់ផ្គង់បណ្តាលឲ្យធ្លាក់ខ្លួនក្រ ឬញាតិដែលមានកំណត់ខាងលើនេះមិនអាចទំនាក់ទំនងបាន ឬបាត់ខ្លួន។

អាពាហ៍ពិពាហ៍ដែលត្រូវបានរំលាយ ដោយសារមរណភាពរបស់សហព័ទ្ធណាម្ខាង អាហារកាតព្វកិច្ចរវាងញាតិ នៅតែមានអត្ថិភាពរវាងសហព័ទ្ធដែលនៅរស់ ជាមួយនឹងញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាព លើកលែងតែសហព័ទ្ធដែលនៅរស់បានរៀបអាពាហ៍ពិពាហ៍ថ្មី ឬបង្ហាញឆន្ទៈផ្តាច់ទំនាក់ទំនងញាតិពន្ធតាមផ្លូវតុលាការ។[59] ប្រសិនបើ ស្ថានភាពផ្លាស់ប្តូរ តុលាការអាចលុបចោលនូវសេចក្តីសម្រេចនោះបាន។[60]

ប្រសិនបើជាជន ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចមានច្រើននាក់ ជននោះត្រូវកំណត់ជាក់លាក់ ដើម្បីឱ្យទទួលបន្ទុកអាហារកាតព្វកិច្ចតាមរយៈការពិភាក្សា ហើយប្រសិនបើការពិភាក្សាទទួលបរាជ័យ តុលាការត្រូវសម្រេចដោយពិចារណាលើលទ្ធភាពទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនដែលមានករណីយកិច្ច ហើយរាប់បញ្ចូលទាំងទំនាក់ទំនងបុគ្គល និងស្ថានភាពផ្សេងៗទៀត។[61]

---

[57] មាត្រា ១១៤០ ដល់មាត្រា ១១៤៤ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[58] មាត្រា ៩៦៦ និងមាត្រា ៩៧១ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[59] មាត្រា ៩៤១ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[60] មាត្រា ១១៤០ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[61] មាត្រា ១១៤១ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

### ៣.៤.៣ បុគ្គលដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច

ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច គឺជាអ្នកដែលទទួលប្រយោជន៍ អំពីរបបអាហារកាតព្វកិច្ច ដោយសារស្ថានភាពដែលកំណត់ដោយច្បាប់ តាមរយៈចំណងញាតិជាអាទិ៍ហើយមានភាគីម្ខាងទៀត ដែលមានកាតព្វកិច្ចបំពេញកិច្ចនេះ ដោយសារតែច្បាប់កំណត់ ឬសេចក្តីសម្រេចរបស់តុលាការចំពោះបុគ្គលនោះ តាមរយៈការផ្គត់ផ្គង់ជីវភាពជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច។[62]

ប្រសិនបើមានជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចច្រើននាក់ គេត្រូវកំណត់យកជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចម្នាក់ ឬច្រើននាក់តាមការពិភាក្សា ហើយប្រសិនបើការពិភាក្សាមិនទទួលបានជោគជ័យនោះទេ តុលាការនឹងធ្វើការសម្រេចដោយពិចារណាទៅលើលទ្ធភាព ទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្តក្នុងទំនាក់ទំនងបុគ្គលរបស់ភាគីហើយស្ថានភាពផ្សេងៗទៀត ផងដែរ។[63]

ប្រសិនបើមានភាពចាំបាច់ បុគ្គលមានសិទ្ធិទទួលអាហារកាតព្វកិច្ច អាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ដោយស្នើសុំឱ្យតុលាការចេញដីកាសម្រេចបង្គាប់ឱ្យចាត់ចែងជាបណ្តោះអាសន្ន។[64] នៅពេលដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងសេចក្តីបញ្ជាក់ដំបូង ហើយប្រសិនបើបំពេញគ្រប់លក្ខខណ្ឌ តុលាការនឹងចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នតាមការស្នើសុំ។ បន្ទាប់មក បុគ្គលមានសិទ្ធិទទួលអាហារកាតព្វកិច្ចត្រូវដាក់បណ្តឹងអង្គសេចក្តី ដែលជាបណ្តឹងទាមទារឱ្យផ្តល់អាហារកាតព្វកិច្ច ហើយបណ្តឹងប្រភេទនេះ គឺជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដោយអ្នកដាក់ពាក្យសុំ ត្រូវបំពេញតាមគ្រប់លក្ខខណ្ឌយ៉ាងត្រឹមត្រូវ (តាមពាក្យសុំ និងដីកាសម្រេច គឺមានភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធនៃអត្ថបទនេះ)។[65]

#### ៣.៤.៣.១ ការផ្គត់ផ្គង់ ការផ្លាស់ប្តូរ ឬការលុបចោល និង អនុប្បទានអាហារកាតព្វកិច្ច

របៀបផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺជាមធ្យោបាយមួយសម្រាប់ធានា ឬរក្សាជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដោយពិចារណាទៅលើ លទ្ធភាពរបស់ជនដែលមានកាតព្វកិច្ច និងស្ថានភាពផ្សេងៗ តាមរយៈការពិភាក្សា ប្រសិនបើការពិភាក្សាទទួលបរាជ័យ តុលាការនឹងធ្វើការសម្រេច។

របៀបផ្គត់ផ្គង់អាហារកាតព្វកិច្ច ជាវិធានការមួយសម្រាប់ជាមូលដ្ឋានក្នុងការកំណត់នូវមធ្យោបាយជាក់លាក់ចំពោះអ្នកដែលមានកាតព្វកិច្ច ដើម្បីកុំឱ្យមានបន្ទុកធ្ងន់ធ្ងរ និងមានលក្ខណៈមិនសមស្របដែលនឹង

---

[62] ដកស្រង់ចេញពីអត្ថបទរៀបរាងដោយ មេធាវី អ៊ីវ ប៉ូលី (អាហារកាតព្វកិច្ច)

[63] ដកស្រង់ចេញពីអត្ថបទរៀបរាងដោយ មេធាវី អ៊ីវ ប៉ូលី (អាហារកាតព្វកិច្ច)

[64] មាត្រា ៤៣ (ច្បាប់នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង) និងមាត្រា ៥៣១ចំណុច “គ” (ក្រមនីតិរដ្ឋប្បវេណីឆ្នាំ២០០៧)

[65] មាត្រា ២៦ (ច្បាប់នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)

នាំឱ្យមិនមានប្រសិទ្ធភាព ហើយប៉ះពាល់ទៅដល់ជីវភាពរបស់អ្នកមានកាតព្វកិច្ចទៅវិញ។ ហេតុដូចនេះហើយ ត្រូវបកស្រាយពាក្យ "ជីវភាព" និងគោលបំណងនៃរបបអាហារកាតព្វកិច្ច ដែលមានខ្លឹមសារថា របបអាហារកាតព្វកិច្ចត្រូវបានបង្កើតឡើង ដើម្បីធ្វើការផ្តល់ប្រាក់ ឬទ្រព្យជាប្រចាំសម្រាប់ទ្រទ្រង់ជីវភាពចាំបាច់របស់ជនដែលមានសិទ្ធិទទួលរបបអាហារកាតព្វកិច្ច ដូចជា អាហារបីពេល ស្នាក់នៅ ស្លៀកពាក់ រៀនសូត្រសមរម្យ ឬព្យាបាលជម្ងឺជាធម្មតា លើសពីនេះ មិនគប្បីអនុវត្តនោះឡើយ។ គោលបំណងនៃរបបអាហារកាតព្វកិច្ច គឺជាការផ្គត់ផ្គង់ជីវភាពរស់នៅ ជាអប្បបរមា ប៉ុន្តែអាហារកាតព្វកិច្ចរវាងសហព័ទ្ធ ដែលកើតចេញពីអានុភាពនៃអាពាហ៍ពិពាហ៍ និងអាហារកាតព្វកិច្ចរបស់ឪពុក ម្តាយចំពោះកូនជាអនីតិជន ដែលកើតចេញពីអានុភាពនៃអំណាចមេបា គឺជាទម្រង់នៃការផ្គត់ផ្គង់ជីវភាពរស់នៅ ដោយតម្រូវឱ្យជនទាំងនេះមានកម្រិតជីវភាពដូចគ្នា។ ផ្ទុយទៅវិញ អាហារកាតព្វកិច្ចរវាងញាតិ ត្រូវបានបកស្រាយថា ត្រូវផ្គត់ផ្គង់កូន ប្រពន្ធ រក្សាជីវភាពរបស់ខ្លួនឱ្យបានសមរម្យទៅនឹងមុខរបរ និងឋានៈរបស់ខ្លួនក្នុងសង្គម ហើយទ្រព្យដែលនៅសល់នឹងក្លាយជាកម្មវត្ថុសម្រាប់ផ្គត់ផ្គង់ជីវភាពញាតិក្រីក្រ ដែលជាទម្រង់នៃករណីយកិច្ចទ្រទ្រង់ជីវភាព។

ប្រសិនបើមានការផ្លាស់ប្តូរស្ថានភាព ក្រោយពីបានពិភាក្សា ឬក្រោយពីមានការសម្រេចសេចក្តីចំពោះជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ឬជនដែលទទួលអាហារកាតព្វកិច្ចជាក់លាក់ ឬរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ភាគីអាចផ្លាស់ប្តូរបាន មានន័យថាទំនាក់ទំនងនៃអាហារកាតព្វកិច្ច អាចត្រូវបានលុបចោល ឬផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពនៃការពិភាក្សា និងប្រសិនបើការពិភាក្សាមិនទទួលបានជោគជ័យ តុលាការនឹងបង្គាប់ឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចមុន។

សិទ្ធិទាមទារអាហារកាតព្វកិច្ច ជាសិទ្ធិផ្តាច់មុខរបស់បុគ្គលដែលត្រូវការចាំបាច់នូវអាហារកាតព្វកិច្ចនោះ ដោយសិទ្ធិនេះមិនអាចប្រើប្រាស់តាមទំនើងចិត្តរបស់ម្ចាស់សិទ្ធិនោះទេ ហើយអាហារកាតព្វកិច្ច ជាសិទ្ធិដែលមានលក្ខណៈដោយចំពោះសម្រាប់បុគ្គល និងជាសិទ្ធិដែលមិនអាចក្លាយជាកម្មវត្ថុនៃអនុប្បទាន ឬការធ្វើប្រទានកម្ម ឬការបង្កើតសិទ្ធិប្រាតិភោគសម្រាប់តតិយជន ឬសម្រាប់វិស័យជំនួញនោះឡើយ ហេតុដូចនេះ អាហារកាតព្វកិច្ចមិនអាចក្លាយជាកម្មវត្ថុនៃការរឹបអូស តាមផ្លូវតុលាការ, មិនអាចធ្វើឧបាទេសកម្ម ហើយមិនអាចធ្វើសន្តតិកម្មបាននោះទេ។[66]

[66] មាត្រា១១៤៧ កថាខណ្ឌទី១, មាត្រា៣៨២ កថាខណ្ឌទី២ និងមាត្រា៤២២ វាក្យខណ្ឌទី២ (ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧)

## ៣.៥ អាហារកាតព្វកិច្ច និងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន

សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយ ដែលមិនរស់នៅជាមួយកូន នៅក្រោយពេលលែងលះ ត្រូវមានករណីយកិច្ចទទួលបន្ទុកសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ករណីយកិច្ចនេះ គឺជាអានុភាពនៃអំណាចមេបា ដែលជាអាហារកាតព្វកិច្ចរវាងឪពុក-ម្តាយ ចំពោះកូនជាអនីតិជន។

ជាផ្នែកមួយនៃករណីឪពុក ម្តាយ មានកូនក្នុងបន្ទុក ព្រោះស្ថានភាពនេះ ជាករណីយកិច្ចរបស់អ្នកមានអំណាចមេបាចំពោះកូនជាអនីតិជន ហើយអ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ច ត្រូវបីបាច់ថែរក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ មួយវិញទៀត ក្នុងករណីលែងលះ "ការសម្រេចអំពីអ្នកមានអំណាចមេបានៅពេលលែងលះ" គឺជាស្ថានភាពមួយ ដែលភាគីម្ខាងទៀតដែលគ្មានអំណាចមេបា ក្រោយការលែងលះ មានកាតព្វកិច្ចការពារផលប្រយោជន៍របស់កូន។[67]

ប្រសិនបើមានការទាមទារអាហារកាតព្វកិច្ចពីញាតិរបស់អនីតិជន ដែលមានទ្រព្យសម្បត្តិដ៏ច្រើនដែលទទួលបានតាមរយៈ មតកសាសន៍របស់ឪពុក ម្តាយខ្លួន ដោយមានអ្នកអាណាព្យាបាលដែលត្រូវបានតែងតាំងដោយឪពុក ម្តាយរបស់អនីតិជនជាអាទិ៍ ហើយញាតិនោះមានគោលបំណងឱ្យអនីតិជនទទួលបន្ទុកនូវអាហារកាតព្វកិច្ច។ ស្ថានភាពនេះ ប្រសិនបើអនីតិជនយល់ព្រមមិនមានបញ្ហានោះទេ ប៉ុន្តែប្រសិនបើអនីតិជនមិនយល់ព្រមអាហារកាតព្វកិច្ចនោះក៏មិនអាចអនុវត្តបានផងដែរ បើទោះបីជាមិនមានកំណត់ជាក់លាក់នៅក្នុងក្រមរដ្ឋប្បវេណីក៏ពិតមែន ប៉ុន្តែជាគោលការណ៍ ច្បាប់តាក់តែងបញ្ញត្តិគាំទ្រផលប្រយោជន៍របស់អនីតិជន។ អាហារកាតព្វកិច្ច គឺជាកាតព្វកិច្ច ឬការចំណាយដែលផ្ទុយពីផលប្រយោជន៍របស់អនីតិជន មូលហេតុនេះដូចមានកំណត់អនីតិជនមិនអាចក្លាយជាជន ដែលមានករណីយកិច្ចទទួលបន្ទុកអាហារកាតព្វកិច្ចនៅក្នុងនោះឡើយហើយគប្បីតម្កល់ឧត្តមផលប្រយោជន៍របស់អនីតិជន នេះជាទ្រឹស្តីទី១ ដែលយើង ហៅថាការបកស្រាយក្រម។ ប៉ុន្តែមានទ្រឹស្តីទី ២ ដែលយើងហៅថា ការអនុវត្តក្រម ដែលមានខ្លឹមសារថា ទោះបីជាអនីតិជនក៏ត្រូវទទួលខុសត្រូវចំពោះអាហារកាតព្វកិច្ចផងដែរ ឱ្យតែបំពេញគ្រប់លក្ខខណ្ឌដូចមានកំណត់។ ចំពោះទ្រឹស្តីទាំងពីរនេះ ទ្រឹស្តីដែលមានប្រជាប្រិយគឺទ្រឹស្តីទី២ ប៉ុន្តែ ប្រសិនបើការអនុវត្តជាបន្តបន្ទាប់ មានការប្រែប្រួល ទ្រឹស្តីទី១ នឹងអាចត្រូវបានយកមកអនុវត្ត។

### ៣.៥.១ អាហារកាតព្វកិច្ច និងអាហារកិច្ច

ច្បាប់បានកំណត់ថា ប្តី ប្រពន្ធ ត្រូវមានជីវភាពរួមគ្នា សហការសង្គ្រោះគ្នាទៅវិញទៅមក បន្ថែមពីនេះដែលប្តី ប្រពន្ធ ត្រូវមានចំណែកបន្ទុកនៃសោហ៊ុយ ដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើ

[67] មាត្រា ១០៣៤ ដល់ ១០៣៧ (ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧)

ទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។ ករណីយកិច្ចនេះ គឺជាអាហារកាតព្វកិច្ចរវាងសហព័ទ្ធ ដែលជាអានុភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់។[68]

ករណីមានការលែងលះ ភាគីដែលគ្មានកំហុសអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ទៅតាមលទ្ធភាពរបស់ភាគីនោះ ឬតាមការព្រមព្រៀងរបស់ភាគី ហើយប្រសិនបើមិនឯកភាពគ្នា តុលាការនឹងសម្រេច ប៉ុន្តែប្រសិនបើជនបានទទួលអាហារកិច្ចបានរៀបអាពាហ៍ពិពាហ៍ថ្មី ជននោះនឹងលែងទទួលបានអាហារកិច្ចបន្តទៀតហើយ។ ក្នុងនិតិវិធីតុលាការគឺជាអានុភាពនៃអាពាហ៍អាចបង្កើន ឬបន្ថយចំនួនអាហារកិច្ច ប្រសិនបើមានសំណូមពររបស់ភាគី ដោយផ្អែកទៅលើលទ្ធភាពរបស់ភាគីដែលផ្តល់អាហារកិច្ចហើយ អាហារកិច្ចក៏អាចផ្តល់ជាប្រាក់ ឬវត្ថុផ្សេងៗ។[69]

ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចរវាងសហព័ទ្ធពិពាហ៍ស្របច្បាប់ ដោយតម្រូវឱ្យជួយសង្គ្រោះគ្នាទៅវិញទៅមក ប៉ុន្តែអាហារកាតព្វកិច្ច សំដៅដល់អាហារកាតព្វកិច្ចរវាងញាតិ ដោយមិនរាប់បញ្ចូលទំនាក់ទំនងសហព័ទ្ធ និងឪពុកម្តាយចំពោះកូនជាអនីតិជននោះឡើយ។[70]

### ៣.៥.២ ការគណនាចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ច

នៅពេលដែលអាចកំណត់ភាគី ខ្លឹមសារ នីតិវិធីនៃការទាមទារ និងវិសាលភាព បន្ទុកអាហារកាតព្វកិច្ច យើងត្រូវកំណត់ចំនួនទឹកប្រាក់នៃអាហារកាតព្វកិច្ចប្រចាំខែ ដោយពិចារណាអំពីស្ថានភាពជីវភាពរបស់បុគ្គលមានករណីយកិច្ចទទួលបន្ទុលអាហាកាតព្វកិច្ច ការចំណាយនានាក្រោយផ្គត់ផ្គង់ជីវភាពគ្រួសារ ស្ថេរភាពនៃសេដ្ឋកិច្ចរបស់ប្រទេស ដើម្បីជាមូលដ្ឋាននៃរូបមន្តមួយដ៏សមរម្យ។

នេះជាដ្យាក្រាមនៃរូបមន្តដែលអនុវត្តនៅប្រទេសជប៉ុន៖[71]

- កម្មវត្ថុនៃអាហារកាព្វកិច្ច = ចំណូលសរុបរបស់អ្នកមានកាតព្វកិច្ច-ពន្ធជាអាទិ៍-ចំណាយលើអាជីវកម្ម-ចំណាយពិសេស
- សោហ៊ុយសម្រាប់ជីវភាពអប្បបរមារបស់បុគ្គលមានសិទ្ធិ = (ថ្លៃស្នាក់នៅ+អាហារបីពេល+សំលៀកបំពាក់ + ថ្លៃពេទ្យធម្មតា)-ចំណូលរបស់អ្នកមានសិទ្ធិ
- ទឹកប្រាក់នៃអាហារកាតព្វកិច្ច = សោហ៊ុយសម្រាប់ជីវភាពអប្បបរមា ឬកម្មវត្ថុនៃអាហារកាតព្វកិច្ចដែលទាបជាង

---

[68] មាត្រា ៩៦៦ និងមាត្រា ៩៧១ (ក្រមនីតិរដ្ឋវេណី ឆ្នាំ២០០៧)

[69] មាត្រា ៧៦ និងមាត្រា ៧៧ (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩)

[70] មាត្រា ១១៤០ ដល់មាត្រា ១១៤៤ (ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[71] ដកស្រង់ចេញពីអត្ថបទរៀបរាងដោយ មេធាវី អ៊ីវ ប៉ូលី (អាហារកាតព្វកិច្ច)

កំណត់ចំណាំ៖[72]

- ពន្ធជាអាទិ៍៖ ពន្ធលើប្រាក់បៀវត្សន៍, ពន្ធជានារ៉ាប់រង។
- ចំណាយលើអាជីវកម្ម៖ ចំណាយចាំបាច់សម្រាប់អាជីវកម្ម។
- ចំណាយពិសេស ចំណាយថេរក្នុងជីវភាពរស់នៅ ដូចជា ការចំណាយជាប្រចាំសម្រាប់អាហារ ប្រពន្ធ ថ្លៃសិក្សាកូន និងការចំណាយជាប្រចាំផ្ទាល់ខ្លួន។
- កម្មវត្ថុនៃអាហារកាតព្វកិច្ច៖ ទឹកប្រាក់ដែលនៅសល់បន្ទាប់ពីចាត់ចែងសម្រាប់ជីវភាពប្រចាំថ្ងៃរបស់អ្នកមានកាតព្វកិច្ច និងគ្រួសារអ្នកមានកាតព្វកិច្ច។
- សោហ៊ុយជីវភាពអប្បបរមា៖ ថ្លៃចំណាយទាបបំផុតដែលអាចទ្រទ្រង់ជីវភាព។
- ទឹកប្រាក់នៃអាហារកតព្វកិច្ច៖ គឺជាទឹកប្រាក់ដែលត្រូវបង់ជាក់ស្តែងរបស់អ្នកមានករណីយកិច្ចទទួលបន្ទុកអាហារកិច្ច ចំពោះអ្នកមានសិទ្ធិទទួលអាហារកតព្វកិច្ច។

ក្នុងករណីមានការលែងលះ តុលាការត្រូវកំណត់ពីអ្នកមានអំណាចមេបា ដោយឆន្ទានុសិទ្ធិ ពោលគឺទោះបីជាមិនមានពាក្យសុំពីភាគីក៏ដោយ។[73] ជាគោលករណ៍ ការកំណត់នេះត្រូវតែធ្វើឡើងតាមការពិភាក្សារបស់សហព័ទ្ធ។[74] ប៉ុន្តែប្រសិនបើមិនអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅ លើផលប្រយោជន៍របស់កូន។[75]

ឧទាហរណ៍ ៖ ឈ្មោះ ក. បានប្តឹងលែងលះពីឈ្មោះ ខ.។ អ្នកទាំងពីរមានកូនម្នាក់ដែលមានអាយុទើប ៨ឆ្នាំប៉ុណ្ណោះ។ អ្នកទាំងពីរទាមទារសិទ្ធិគ្រប់គ្រងចិញ្ចឹមកូនរៀងខ្លួន។ ឈ្មោះ ក. មានរបរជាកសិករ ចំណែកឯឈ្មោះ ខ ជាប្រពន្ធពុំមានប្រាក់ចំណូលអ្វីទេ។ ក៏ប៉ុន្តែឈ្មោះ ក. ចូលចិត្តផឹកស្រាស្រែកឡូឡាជេរគេជេរឯង។ ក្នុងករណីនេះ ទោះបីជាឈ្មោះ ក. មានមុខរបរ មានប្រាក់ចំណូលក៏ដោយ ក៏ចរិតលក្ខណៈរបស់ឈ្មោះ ក. ដែលចូលចិត្តផឹកស្រា ស្រែកឡូឡា ជេរគេជេរឯង អាចធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់កូនដែលរស់នៅជាមួយ។ ហេតុដូច្នេះ តុលាការអាចសម្រេចប្រគល់អំណាចមេបាលើកូនទៅឱ្យ ឈ្មោះ ខ. ជាម្តាយ ដើម្បីគ្រប់គ្រងវិញបាន។

ម្យ៉ាងវិញទៀត ប្រសិនបើមានការលែងលះ នៅពេលដែលកូនមិនទាន់កើតនៅឡើយ ម្តាយគឺជាអ្នកមានអំណាចមេបាលើកូនដែលបានកើតមកនេះ។ ក៏ប៉ុន្តែក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នក

[72] ដកស្រង់ចេញពីអត្ថបទរៀបរាងដោយ មេធាវី អ៊ីវ ប៉ូលី (អាហារកាតព្វកិច្ច)
[73] មាត្រា ២២ (កថាខណ្ឌទី ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)
[74] មាត្រា ១០៣៧ (កថាខណ្ឌទី ១ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)
[75] មាត្រា ១០៣៧ (កថាខណ្ឌទី ៣ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

មានអំណាចមេបាលើកូនបាន តាមរយៈការពិភាក្សារវាងឪពុកម្ដាយ។[76] ផ្ទុយទៅវិញ ប្រសិនបើមិនអាចពិភាក្សាគ្នាបានទេ តុលាការជាអ្នកសម្រេច នៅពេលដែលមានពាក្យសុំរបស់ឪពុក ដោយផ្អែកតាម ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

ចំពោះភាគីដែលមិនមានអំណាចមេបាលើកូន គាត់មាន សិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងកូន និងមានករណីកិច្ចទទួលបន្ទុកលើ សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។[77] ជាគោលការណ៍ ការកំណត់ពីបញ្ហានេះ ត្រូវធ្វើឡើងដោយផ្អែកតាមការពិភាក្សារបស់ឪពុកម្ដាយ ហើយនៅក្នុងករណីដែលមិនអាចពិភាក្សាគ្នាបានទេ តុលាការជាអ្នកកំណត់ តាមការទាមទាររបស់ឪពុក ឬម្ដាយណាម្ខាង។ ពាក់ព័ន្ធនឹងការសម្រេចសេចក្ដីពីការចូលជួប និងប្រាស្រ័យទាក់ទង តម្រូវឱ្យតុលាការធ្វើការពិចារណាទៅលើផលប្រយោជន៍កូនជាអាទិភាព។ ក្នុងន័យនេះតុលាការធ្វើការពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ស្ថានភាពសុខភាព ស្ថានភាពរបស់កូន បំណងរបស់កូន បំណងរបស់ភាគីទាំងសង ព្រមទាំងស្ថានភាពផ្លូវចិត្តរបស់ភាគីទាំងសងខាងជាដើម។ សម្រាប់សោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន បានតម្រូវឱ្យតុលាការពិចារណាទៅលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយទាំងសងខាង។ ជាទូទៅ ការតម្រូវឱ្យភាគីម្ខាងបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន គឺធ្វើឡើងដោយកំណត់ទៅតាមខែនីមួយៗ ហើយតុលាការនឹងសម្រេចថា ត្រូវបង់សោហ៊ុយនេះចាប់ពីពេលណា រហូតដលពេលណាជាកំណត់ជាក់លាក់។

ឧទាហរណ៍ ៖ សំភី និង រស្មី បានលែងលះគ្នា។ តុលាការបានសម្រេចប្រគល់កូនឈ្មោះ ដារ៉ា ដែលមានអាយុទើបតែ ៥ឆ្នាំ ឱ្យទៅ រស្មី ជាម្ដាយ ដើម្បីចិញ្ចឹមបីបាច់ថែរក្សា។ ក្នុងករណីនេះ មានន័យថា រស្មី ជាអ្នកមានអំណាចមេបាលើ ដារ៉ា។ ចំណែកឯ សំភី ជាឪពុកដែលពុំមានអំណាចមេបាលើ ដារ៉ា ទេ។ ទន្ទឹមនឹងនេះ តុលាការបានសម្រេចឱ្យ សំភី ចូលជួបប្រាស្រ័យទាក់ទងជាមួយនឹង ដារ៉ាម្ដងក្នុងមួយសប្ដាហ៍ ដោយកំណត់យកថ្ងៃអាទិត្យចាប់ពីម៉ោង ១៥៖០០ រហូតដល់ម៉ោង ១៧៖០០ នៅលំនៅឋានរបស់ រស្មី។ ត្រង់ចំណុចនេះគឺជាសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងរបស់ សំភី។ ក្រៅពីនេះ តុលាការបានសម្រេចឱ្យ សំភី ត្រូវបងប្រាក់ដើម្បីឱ្យ រស្មី ចិញ្ចឹមបីបាច់ថែរក្សា ដារ៉ា ចំនួន ១លានរៀល ក្នុងមួយខែ ដោយគិតចាប់ពីពេលសេចក្ដីសម្រេចលែងលះចូលជាស្ថាពរ រហូតដល់កូនមានកូន ឬក៏ពេលខ្លះគេប្រើពាក្យថា “ អាហារកិច្ច”។ គប្បីគូសបញ្ជាក់ថា ទាក់ទងនឹងការសម្រេចសេចក្ដីពីការកំណត់អ្នកមាន អំណាចមេបា ឬ ការចាត់ចែងទាក់ទំនងនឹងការបីបាច់រក្សាកូនដូច

[76] មាត្រា ១០៣៧ (កថាខណ្ឌទី ២ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)
[77] មាត្រា ១០៤០ (កថាខណ្ឌទី ១ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

បារៀបរាប់ ខាងលើនេះ តុលាការត្រូវពិចារណាថ្លឹងថ្លែងទៅលើយោបល់របស់កូន ឲ្យសមស្របទៅតាមអាយុ នឹងសភាពចាស់ទុំរបស់កូននោះ។[78]

សូមធ្វើការកត់សម្គាល់ជាពិសេសថា ទោះបីជាតុលាការបានសម្រេចសេចក្តីពីការកំណត់អ្នកមាន អំណាចមេបា ការចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន ព្រមទាំងសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូនរួច ហើយក៏ដោយ ក៏សេចក្តីសម្រេចទាំងនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរបានដែរ។[79]

ឧទាហរណ៍ ៖ លក្ខិណា បានលែងលះគ្នាពី សារ៉ាយ ហើយនាងត្រូវបានតុលាការសម្រេចប្រគល់ អំណាចមេបាលើកូនម្នាក់ដែលជាអនីតជន។ មូលហេតុនៃការសម្រេចយ៉ាងដូច្នេះ គឺមកពី សារ៉ាយ តែងតែផឹក ស្រាស្រវឹងជាំប្រចាំ។ ឧបមាថា សារ៉ាយ បានកែប្រែខ្លួនដោយឈប់ផឹកស្រាបង្ករឿងរ៉ាវដល់អ្នកដទៃទៀតហើយ ចំណែកឯ លក្ខិណៈ វិញមានការខ្វះខាតយ៉ាងខ្លាំងក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន ហើយពេលខ្លះ លក្ខិណា បានឱ្យកូនដើរសុំទានយកប្រាក់មកផ្គត់ផ្គង់ជីវភាពទៀតផង។ ក្នុងស្ថានភាពបែបនេះ បើសិនជា សារ៉ាយ ស្នើសុំ ឱ្យ តុលាការផ្លាស់ប្តូរអ្នកមានអំណាចមេបាលើកូន ពោលគឺ ទាមទារឱ្យ លក្ខិណា ប្រគល់កូនមកឱ្យ សារ៉ាយ ចិញ្ចឹមបីបាច់ថែរក្សាវិញម្តងនោះ សារ៉ាយ មានឱកាសច្រើននឹងទទួលបានអំណាចមេបាលើកូនវិញ។

ដូចគ្នាដែរ ក្នុងសម្មតិកម្មខាងលើ ដែលតុលាការបានសម្រេចឱ្យ សំភី ជាឪពុកបងសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនចំនួន ១លានរៀល ក្នុងមួយខែ ក៏ប៉ុន្តែក្រោយកម សំភី បានបាត់បងការងារ ដែលមិន អាចរកចំណូលបានច្រើនដូចពីមុន។ ករណីនេះ សំភី អាចដាក់ពាក្យសុំទៅតុលាការឱ្យបន្ថយចំនួនសោហ៊ុយ នេះបាន (ឧទាហរណ៍៖ សម្រេចឱ្យបន្ថយសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន មកត្រឹម ៤សែនរៀល ក្នុង មួយខែវិញ)។

លើសពីនេះទៀត ប្រសិនបើភាគីដែលមានករណីយកិច្ចត្រូវបង់សោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សា កូន ឬអាហារកិច្ច តាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការ ហើយបែរជាមិនព្រមគោរពតាមសេចក្តីសម្រេច នេះ នឹងនាំឱ្យមានទណ្ឌកម្មពីប្រភេទគឺ៖[80]

- **ទណ្ឌកម្មរដ្ឋប្បវេណី**៖ ម្ចាស់បំណុល (ជនដែលមានសិទ្ធិទាមទារអាហារកិច្ច) អាចដាក់ពាក្យសុំ ដើម្បី ឱ្យមានការអនុវត្តករណីយកិច្ចរបស់ខ្លួន ដូចជាការរឹបអូសទ្រព្យសម្បត្តិជាដើម។
- **ទណ្ឌកម្មព្រហ្មទណ្ឌ**៖ ការមិនគោរពតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ ដោយមិនព្រមបង់ អាហារកិច្ចក្នុងរយៈពេល ២ខែយ៉ាងតិច នូវអាហារកាតព្វកិច្ចឱ្យសហព័ទ្ធ ឬអតីតសហព័ទ្ធរបស់ខ្លួន

[78] មាត្រា ២២ (កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)

[79] មាត្រា ១០៣៩ និង មាត្រា ១០៤០ (កថាខណ្ឌទី ៥ ក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧)

[80] សៀវភៅរៀបរៀងដោយលោកគ្រូ រុណ ពណ្ណរិទ្ធ និង អ្នកគ្រូ ចាំង ស៊ីណាត ស្តីពី នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ)

ដល់កូនជាអនីតិជន ដល់បច្ចាញាតិ ឬបុព្វញាតិ ឬដល់ញាតិផ្សេងទៀតរបស់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ២លានរៀល[81]។ សរុបសេចក្តីមក អំពើនេះត្រូវបានចាត់ទុកថាជាបទល្មើសដែលមានឈ្មោះថា បទបោះបង់គ្រួសារ។

[81] មាត្រា ៣២៤ (ក្រមនីតិព្រហ្មទណ្ឌ)

# សេចក្តីសន្និដ្ឋាន

ក្រោយបានបញ្ចប់ការសិក្សាស្រាវជ្រាវ ក្រោមប្រធានបទ "អានុភាពនៃការលែងលះ" រួចមកនាងខ្ញុំយល់ឃើញថា ចំណងអាពាហ៍ពិពាហ៍មួយអាចកើតឡើងបាន លុះត្រាតែគូភាគីគោរពទៅតាមនីតិវិធីដែលច្បាប់បានចែង ក៏ដូចជាលក្ខខណ្ឌនានាដែលច្បាប់តម្រូវឱ្យភាគីនីមួយៗអនុវត្តតាម។ ជាងនេះទៅទៀត ពួកគាត់ត្រូវតែទៅចុះសំបុត្រអាពាហ៍ពិពាហ៍បើពុំនោះទេ អាពាហ៍ពិពាហ៍របស់ពួកគាត់ពុំមានចំណងគតិយុត្តអ្វីឡើយ។

ផ្ទុយទៅវិញ ប្រសិនបើចំណងអាពាហ៍ពិពាហ៍ ដែលស្របច្បាប់របស់ពួកគាត់មានភាពរង្គោះរង្គើរ ឬជួបប្រទះនូវបញ្ហាមួយចំនួន ដែលនាំឱ្យឈានដល់ដំណាក់កាល ដែលមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ទោះបីជាពួកគាត់ទាំងពីរធ្លាប់ទទួលបាននូវការផ្សះផ្សា ដែលពេលខ្លះការផ្សះផ្សានោះទទួលបានជោគជ័យ ហើយបញ្ហាមួយចំនួនក៏មិនអាចធ្វើការផ្សះផ្សាបាន ដែលមូលហេតុទាំងនេះហើយ ទើបធ្វើឱ្យចំណងអាពាហ៍ពិពាហ៍របស់ពួកគាត់ឈានដល់ការលែងលះ។

ក្នុងករណីដែលពួកគាត់ចង់លែងលះគ្នា សហព័ទ្ធទាំងពីរត្រូវតែដាក់ពាក្យសុំលែងលះទៅតុលាការ និងត្រូវឆ្លងកាត់នូវនីតិវិធីតាមផ្លូវតុលាការជាច្រើនដំណាក់កាលទៀត ទើបពួកគាត់អាចធ្វើការលែងលះគ្នាដាច់ស្រេចបាន។ ដោយយោងតាមបញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និងច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ បានការពារនូវផលប្រយោជន៍ជាច្រើនរបស់សហព័ទ្ធ។ បន្ទាប់ពីពួកគាត់បានលែងលះគ្នាហើយ មិនថាជាភាគីប្តី ឬ ប្រពន្ធ ព្រមទាំងកូនផងដែរ ត្រូវទទួលបាននូវការការពារពីច្បាប់។ នៅពេលដែលការលែងលះនោះមានអានុភាពហើយនោះ សហព័ទ្ធទាំងពីរត្រូវតែធ្វើការព្រមព្រៀងគ្នានូវការបែងចែកទ្រព្យសម្បត្តិ ការផ្តល់អាហារកាតព្វកិច្ចដល់កូន និងដល់អតីតសហព័ទ្ធណាមួយ ដែលមានការខ្វះខាតជីវភាពក្រោយការលែងលះ ការប្រគល់អំណាចមេបាដោយឱ្យកូនទៅរស់នៅជាមួយសហព័ទ្ធណាមួយ និងសហព័ទ្ធដែលមានអំណាចមេបាត្រូវផ្តល់ឱកាសឱ្យសហព័ទ្ធដែលមិនមានអំណាចមេបា បានជួបប្រាស្រ័យទាក់ទងជាមួយកូនផងដែរ។

ជាចុងបញ្ចប់នៃសារណាមួយនេះ នាងខ្ញុំចង់ឱ្យបុគ្គលគ្រប់រូបមុននឹងសម្រេចចិត្តចាប់ដៃគ្នាបង្កើតនូវចំណងអាពាហ៍ពិពាហ៍ ដើម្បីបង្កើតជាក្រុមគ្រួសារមួយនៅក្នុងសង្គម ត្រូវតែធ្វើការត្រិះរិះពិចារណាឱ្យបានម៉ត់ចត់ គ្រប់ជ្រុងជ្រោយថាខ្លួនអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដើរតួនាទីជាស្វាមី ជាភរិយា ជាឪពុក ជាម្តាយ ដ៏ល្អបានហើយ ឬ នៅ។ ម្យ៉ាងវិញទៀត ដើម្បីជៀសវាងនូវការបែកបាក់ក្រុមគ្រួសាររបស់ពួកគាត់ ដែលការបែកបាក់នោះធ្វើឱ្យបាត់បង់នូវផលប្រយោជន៍ជាខ្លាំង ជាពិសេសនោះចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធនិងពុំមានសេចក្តីសុខឡើយ។

# អនុសាសន៍

បន្ទាប់ពីបានសរសេរ និង រៀបចំនូវសារណាបញ្ចប់ការសិក្សានេះរួចមក នាងខ្ញុំឃើញថា ប្រជាជនមួយចំនួនមិនមានការយល់ដឹងអំពីរឿងអាពាហ៍ពិពាហ៍ និងការលែងលះនៅឡើយ ដោយពួកគាត់ពុំបានទទួលនូវការផ្សព្វផ្សាយអំពីឯកសារច្បាប់ដែលពាក់ព័ន្ធ ដើម្បីធ្វើការរៀបអាពាហ៍ពិពាហ៍ និងការលែងលះគ្នាជាដើម។ ពិសេស ប្រជាជនដែលរស់នៅតំបន់ជនបទដាច់ស្រយាល ពុំបានយល់ដឹងអំពីនីតិវិធី ដែលនាំឱ្យមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ ជាក់ស្តែងពួកគាត់អនុវត្តតាមទំនៀមទំលាប់ ប្រពៃណី ដែលមានតាំងពីដូនតាមកម្លេះ ហើយពួកគាត់គ្រាន់តែរៀបចំប្រារព្ធធ្វើនូវកម្មពិធីអាពាហ៍ពិពាហ៍ ដើម្បីជាការបើកបង្ហាញថា កូនកំលោះកូនក្រមុំ ជាស្វាមីភរិយានឹងគ្នារួចហើយ ដោយពុំបានបំពេញទៅតាមផ្លូវច្បាប់ត្រឹមត្រូវ ដូចជាគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍ជាដើម។ មួយវិញទៀត នៅពេលដែលមានវិវាទកើតឡើងរវាងប្តី និងប្រពន្ធ ពួកគាត់មិនដឹងថាតើត្រូវប្តឹងទៅសមត្ថកិច្ចណាមួយឲ្យជួយដោះស្រាយ ដើម្បីទទួលបាននូវភាពយុត្តិធម៌ និងអានុភាពនៅក្រោយពេលលែងលះទៀតផង។

ដោយសារកង្វះខាតនូវចំណេះដឹងមួយចំនួននេះហើយ ទើបនាងខ្ញុំ សូមចូលរួមនូវការផ្តល់ជាមតិយោបល់ខ្លះៗក្នុងគោលបំណង ដើម្បីធ្វើការកែតម្រូវនូវចំណុចទាំងនោះដូចជា ៖

- រដ្ឋាភិបាល ត្រូវផ្តល់ការផ្សព្វផ្សាយជាសាធារណៈ ដើម្បីឲ្យប្រជាជនបានយល់ច្បាស់ អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ និងនីតិវិធីនៃការលែងលះ ដើម្បីជាភាពងាយស្រួលដល់ពួកគាត់ ហើយក៏ជាចំណេះដឹងបន្ថែមទៀតសម្រាប់ពួកគាត់បើប្រាស់នៅពេលណាដែលគាត់ជួបប្រទះនូវបញ្ហាទាំងនោះ ហើយក៏ជាវិធីមួយដើម្បីជួយកាត់បន្ថយនូវការលែងលះគ្នាផងដែរ។
- សហព័ទ្ធទាំងពីរ ត្រូវតែស្មោះស្ម័គ្រមួយនឹងមួយ ដោយពុំមានចិត្តវៀចវេរ ឬមិនផិតក្បត់គ្នា ដើម្បីរក្សានូវចំណងអាពាហ៍ពិពាហ៍កុំឲ្យឈានដល់ការលែងលះគ្នា ដែលជាមូលហេតុធ្វើឲ្យគ្រួសារដែលធ្លាប់តែមានសុភមង្គល ប្រែទៅជាគ្រួសារដែលបែកបាក់ទៅវិញ។
- រាល់កំហុសតិចតួចដែលសហព័ទ្ធណាម្ខាងបានប្រព្រឹត្ត ត្រូវតែចេះអត់អោនអធ្យាស្រ័យឲ្យគ្នាទៅវិញទៅមក ដើម្បីបញ្ចៀសនូវការមិនចុះសម្រុង ឬការបែកបាក់៕

# ឯកសារយោង

## ➢ ច្បាប់ និង បទបញ្ញត្តិផ្សេងៗ

១.រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២.ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦ ។

៣.ក្រមនីតិរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

៤.ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ២០១១

៥.ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

៦.ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១

៧.សៀវភៅកំណត់ពន្យល់អំពីមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

៨.សៀវភៅកំណត់ពន្យល់អំពីមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី

៩.ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង  តារាងឧបសម្ព័ន្ធ

១០.សៀវភៅកំណត់ពន្យល់អំពីមាត្រានីមួយៗនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង និង  តារាងឧបសម្ព័ន្ធ

១១.សៀវភៅកំណត់ពន្យល់អំពីមាត្រានីមួយៗនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

១២.ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

១៣.ច្បាប់ស្តីពីឯកពន្ធភាពចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៦

## ➢ សៀវភៅ និង ឯកសារផ្សេងៗ

១.សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុនភាគទី១ ទំព័រ៨៧-៨៨

២.សៀវភៅរៀបរៀងដោយលោកគ្រូ រុណ ពណ្ណារិទ្ធ និង អ្នកគ្រូ ចាំង ស៊ីណាត ស្តីពី នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ ( ថ្ងៃ អង្គារ-ពុធទី ១១-១២ ខែ មិថុនា ឆ្នាំ ២០១៣ )

៧.សៀវភៅសារណារបស់បងៗជំនាន់មុន

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១៖** នីតិវិធីនៃការដាក់ពាក្យលែងលះ នៃអាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀង

**ឧបសម្ព័ន្ធទី ២ ៖** នីតិវិធីនៃការដាក់ពាក្យលែងលះនៃអាពាហ៍ពិពាហ៍ដោយមានពាក្យបណ្តឹង

# ឧបសម្ព័ន្ធទី ១
# នីតិវិធីនៃការដាក់ពាក្យលែងលះនៃអាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

<table>
<tr><td colspan="2">បង្គាប់មកចុងចម្លើយឈ្មោះ ................ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និងភាគី)</td><td>សំណុំរឿងក្តីរដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ................ ចុងចម្លើយ: ................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ២០២០ វេលាម៉ោង៨:០០ ព្រឹក<br>មន្ទីរស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល ☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃព្រហស្បតិ៍ ៩ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣<br>ធ្វើនៅរតនគិរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០<br>**ចៅក្រម**</td></tr>
</table>

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

<table>
<tr><td colspan="2">បង្គាប់មកឈ្មោះ ................ ជាដើមចោទ ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និងភាគី)</td><td>សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៦៨/២០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០២០<br>ដើមចោទឈ្មោះ ................ ចុងចម្លើយ: ................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០២០ វេលាម៉ោង៨:០០ ព្រឹក<br>មន្ទីរស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ<br>(សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបាន បង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ៣.៨៩៩$ (បីពាន់បួនរយកៅសិបប្រាំបួនដុល្លាអាមេរិក)។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃព្រហស្បតិ៍ ៩ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣<br>រតនគិរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០<br>**ចៅក្រម**</td></tr>
</table>

**បញ្ជាក់**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

*សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង*
*លេខ.........................*

**កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ចាក់ដំបូង**

*បានឃើញមាត្រា១១៣ ដល់មាត្រា១២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស់ឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។*

*សញ្ញាណរឿងក្តី*

*ប្តឹងសុំតុលាការអនុវត្តដោយបង្គំដូចខាងក្រោម*

*១. សុំលែងលះរវាងពីប្តីឈ្មោះ ...................... និងប្រពន្ធឈ្មោះ ...................... ។*

*២. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន១នាក់ឈ្មោះ ...................... ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ...................... ។*

*លោក ................ ប្រធាននិងចៅក្រមសាលាដំបូងខេត្តរតនគិរី*

*លោក ...................... ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី*

***អ្នកដាក់ពាក្យសុំឈ្មោះ*** *...................... ភេទស្រី អាយុ២២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។*

***ភាគីម្ខាងទៀតឈ្មោះ*** *.................. ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។*

***ឆ្នាំពីរពាន់មួយម្ភៃ ខែឧសភា ថ្ងៃទីប្រាំពីរ វេលាម៉ោងដប់ និងសាមសិបនាទីព្រឹក*** *នៅសាលាដំបូងខេត្តរតនគិរី បានធ្វើនីតិវិធីផ្សះផ្សារដល់គូភាគីដើម្បីឲ្យបានរស់នៅជាប្តីប្រពន្ធនិងគ្នាវិញ ប៉ុន្តែគូភាគីនៅតែមិនអាចរស់នៅជាមួយគ្នាបាន ហេតុនេះតុលាការបញ្ឈប់នីតិវិធីផ្សះផ្សារ ដោយបន្តនីតិវិធីបញ្ចាក់ដំបូងរវាងអ្នកដាក់ពាក្យសុំឈ្មោះ .................. ជាមួយនិងភាគីម្ខាងទៀតឈ្មោះ ............ ។*

*-អ្នកដាក់ពាក្យសុំឈ្មោះ ................................. បានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នៅសាលាសង្កាត់បឹងកន្សែង។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍នាងខ្ញុំមានកូនចំនួន១នាក់ ។ នាងខ្ញុំសុំសិទ្ធគ្រប់គ្រង ចំពោះទ្រព្យសម្បត្តិរួម និងប្រាក់បំណុល នាងខ្ញុំនិងប្តីបានព្រមព្រៀងគ្នារួចរាល់*

*អស់ហើយ សុំឲ្យលោកចៅក្រម ទទួលស្គាល់ការព្រមព្រៀងនេះផង មានក្នុងកំណត់ហេតុ ផ្សះផ្សាសម្របសម្រួលលេខ ២៤/០១,០៤,២០១៩ ។*

*មកដល់ដំណាក់កាលនេះ នាងខ្ញុំអស់មនោសញ្ចេតនានិងគ្នាហើយ នាងខ្ញុំបានធ្វើកិច្ចព្រមព្រៀងលែងលះ ជាមួយភាគីប្តី បន្ទាប់មកបានដាក់ពាក្យសុំឲ្យតុលាការសម្រេចលែងលះតាមការព្រមព្រៀង និងសុំសិទ្ធិគ្រប់គ្រងកូនចំនួនមួយនាក់។*

*-ភាគីម្ខាងទៀតឈ្មោះ ................ បានធ្វើសេចក្តីថ្លែងការណ៍តបថាៈ ខ្ញុំបាទឯកភាពតាមសេចក្តីថ្លែងការណ៍របស់ភាគីអ្នកដាក់ពាក្យសុំ ដោយយល់ព្រមលែងលះពីប្រពន្ធឈ្មោះ ...................... និងយល់ព្រមប្រគល់កូនចំនួន១នាក់ឲ្យទៅអ្នកដាក់ពាក្យសុំ។ ចំពោះទ្រព្យសម្បត្តិរួម និងប្រាក់បំណុលរូបខ្ញុំបាទនិងប្រពន្ធបានព្រមព្រៀងគ្នារួចរាល់អស់ហើយ។*

*រីឯប្រាក់អាហារកិច្ចសុំបង់ជូនក្នុងមួយខែៗ ចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) រហូតដល់កូនធំពេញវ័យ ។*

*-អ្នកដាក់ពាក្យសុំឈ្មោះ ...................... បានធ្វើសេចក្តីថ្លែងការណ៍ថាៈ នាងខ្ញុំឯកភាព ចំពោះសេចក្តីថ្លែងការណ៍របស់ភាគីប្តី ដោយមិនមានសំណូមពរអ្វីទៀតនោះឡើយ។*

***យើងបានបញ្ចប់សេចក្តីបញ្ជាក់ដំបូង នៅវេលាម៉ោងដប់មួយ ព្រឹកថ្ងៃខែឆ្នាំដដែល។***

***បានអានកំណត់ហេតុនៃនីតិវិធីនៃសេចក្តីបញ្ជាក់ដំបូងជូនភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ធ្វើយថាត្រឹមត្រូវសូមផ្តិតមេដៃទុកជាភស្តុតាង ។***

| អ្នកដាក់ពាក្យសុំ | ភាគីម្ខាងទៀត | ក្រឡាបញ្ជី | ចៅក្រម |
|---|---|---|---|
| ...................... | ...................... | | |

៣-គូភាគីបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ០៣៧ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ នៅសាលាសង្កាត់ បឹងកន្សែង ក្រុងបានលុង បញ្ជាក់ថា គូភាគីពិតជាមានអាពាហ៍ពិពាហ៍ស្របច្បាប់ប្រាកដមែន។ ដូចនេះដើម្បីចៀសវាងបញ្ហាផ្សេងៗកើតឡើងជាយថាហេតុ គប្បីតុលាការសម្រេចឲ្យលែងលះរវាងគូភាគីតាមការព្រមព្រៀង។

៤-នៅក្នុងនីតិវិធីបញ្ជាក់ដំបូង ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

ក-លែងលះជាប្តី-ប្រពន្ធ

ខ-ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួនមួយនាក់ឈ្មោះ .................... ភេទស្រី កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ឲ្យទៅឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ .................... ជាម្តាយអ្នកគ្រប់គ្រង។

៥- តាមបញ្ញត្តិមាត្រា៤៧ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីកាតព្វកិច្ចរបស់មាតាបិតា ក្នុងការរួមគ្នាចិញ្ចឹមបីបាច់ ថែរក្សាកូនឲ្យក្លាយទៅជាពលរដ្ឋល្អក្នុងសង្គម និងមាត្រា ១០៣៧ ក្រមរដ្ឋប្បវេណី (ការសម្រេចអំពីអ្នកមានអំណាចមេបា) គប្បីគូភាគី រួមគ្នាបំពេញកាតព្វកិច្ចរបស់ខ្លួនតាមបញ្ញត្តិច្បាប់។

៦-ដោយសម្ព័ន្ធភាពជីវិតអាពាហ៍ពិពាហ៍របស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតបានធ្វើឲ្យសហព័ទ្ធម្ខាងៗទទួលរងសម្ពាធផ្លូវចិត្តធ្វើឲ្យផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ។ គប្បីតុលាការលើកយកការស្នើសុំ និងការព្រមព្រៀងគ្នារបស់ភាគីតាមនីតិវិធីបញ្ជាក់ដំបូង មកសម្រេចដោយយោងតាមបញ្ញត្តិមាត្រា៩៧៨ និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៧-ភាគីនៃអាពាហ៍ពិពាហ៍ មានបំណងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ គប្បីតុលាការទទួលយកមកពិចារណា និងសម្រេចតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

៨-ទ្រព្យសម្បត្តិរួមនិងប្រាក់បំណុល នៅក្នុងកំណត់ហេតុនៃនីតិវិធី សេចក្តីបញ្ជាក់ដំបូង ភាគីអ្នកដាក់ពាក្យសុំឈ្មោះ .................... និងភាគីម្ខាងទៀតឈ្មោះ .................... បានបញ្ជាក់ថាខ្លួនបានព្រមព្រៀងគ្នារួចរាល់អស់ហើយ ចំណុចនេះមិនគប្បីតុលាការលើកមកធ្វើការពិចារណានោះឡើយ ។

៩-នៅក្នុងដំណាក់កាលនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតបានឯកភាពគ្នាក្នុងការបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូន ក្នុងមួយខែៗចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) គប្បីតុលាការសម្រេចតាមការព្រមព្រៀង ។

ជាការសន្និដ្ឋាន គប្បីសម្រេចលែងលះរវាងអ្នកដាក់ពាក្យសុំឈ្មោះ .................... និងភាគីម្ខាងទៀតឈ្មោះ .................... តាមពាក្យសុំលែងលះតាមការព្រមព្រៀងរបស់ភាគី ទៅតាមបញ្ញត្តិមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណីមិនមែន
បណ្តឹងលេខ..............................
ដីកាសម្រេចលេខ: ............ /២០

## ដីកាសម្រេច

យើង ............... ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

អមដោយលោក ................. ជាក្រឡាបញ្ជី

-បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នសរ៍ខែ ០៦ ចុះថ្ងៃទី ០២១/០៧០១/រកម/កក្កដា ឆ្នាំ២០០៦។

-បានបញ្ចប់នីតិវិធីបញ្ជាក់ដំបូងនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ៦៤ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០។

**រវាង**

អ្នកដាក់ពាក្យសុំឈ្មោះ ................... ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

**នឹង**

ភាគីម្ខាងទៀតឈ្មោះ ............. ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

កម្មវត្ថុនៃបណ្តឹង

១. សុំលែងលះរវាងពីប្តីឈ្មោះ ............. និងប្រពន្ធឈ្មោះ ................. ។

២. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន១នាក់ឈ្មោះ ......... ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ................. ។

បានឃើញកំណត់ហេតុស្តីពីសេចក្តីបញ្ជាក់ដំបូងចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ រវាងអ្នកដាក់ពាក្យសុំឈ្មោះ .................... និងភាគីម្ខាងទៀតឈ្មោះ ................ ដោយភាគីទាំងពីរស្នើសុំឲ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំរបស់ខ្លួនដោយលែងលះតាមការព្រមព្រៀង។

**យល់ឃើញថា**

១-ពាក្យសុំចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់អ្នកដាក់ពាក្យសុំឈ្មោះ .................... និងភាគីម្ខាងទៀតឈ្មោះ ............. ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២- នៅតំណាក់កាលនៃនីតិវិធីបញ្ជាក់ដំបូង តុលាការបានព្យាយាមធ្វើការផ្សះផ្សារួចហើយ ប៉ុន្តែគូភាគីនៅតែមិនព្រមសះជានឹងគ្នាវិញទេ ដោយគូភាគីនៅតែស្នើសុំឲ្យតុលាការ សម្រេចលែងលះឲ្យខ្លួនដដែល។ គប្បីតុលាការលើកយកការស្នើសុំរបស់ភាគីទាំងពីរមកពិចារណា។

**ហេតុដូច្នេះសម្រេច**

ក/-ឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................. និងភាគីម្ខាងទៀតឈ្មោះ ............... ផ្តាច់សមគ្គសង្វាសតាមការព្រមព្រៀងរបស់គូភាគី មាត្រា ៧៧៨ និងមាត្រា ៧៧៩ នៃក្រមរដ្ឋប្បវេណី។

ខ/-ប្រគល់សិទ្ធិចិញ្ចឹម បីបាច់ ថែរក្សាកូនចំនួនមួយនាក់ឈ្មោះ ................. ភេទស្រី កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ .................. ជាម្តាយជាអ្នកមានអំណាចមេបាតាមមាត្រា ៤៧ រដ្ឋធម្មនុញ្ញ និង មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

គ/-ភាគីដែលមិនបានគ្រប់គ្រង ថែរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូនបានគ្រប់ពេលវេលាតាមមាត្រា ១០៣៨ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។ ភាគីដែលគ្រប់គ្រងថែរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលឲ្យភាគីម្ខាងទៀតបានបំពេញកិច្ចការនេះ។

ឃ/-បង្គាប់មកឈ្មោះ ................ បង់ប្រាក់អាហារកិច្ចចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) សម្រាប់ចិញ្ចឹមកូនរហូតដល់ធំពេញវ័យជូនទៅអ្នកស្រី ជឿន ច័ន្ទលីដា ក្នុងមួយខែៗ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ ។

ង/-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំដែលបានបង់រួច។

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ចៅក្រម**

..............................

---

**បានឃើញនិងឯកភាព**

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ប្រធានសាលាដំបូង**

បានចម្លងតាមច្បាប់ដើម

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

# ឧបសម្ព័ន្ធទី ២

# នីតិវិធីនៃការដាក់ពាក្យលៃខលះ

# នៃអាពាហ៍ពិពាហ៍ដោយមានពាក្យបណ្ដឹង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងលែងលះ

**ដើមចោទ៖** ឈ្មោះ .................... ភេទស្រី អាយុ ៣០ ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅបច្ចុប្បន្នភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី លេខទូរស័ព្ទ ០៩៧ ៦៩ ៣២ ០០៦។

**ចុងចម្លើយ៖** ឈ្មោះ ................ ភេទប្រុស អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរធ្វើចំការ មានទីលំនៅបច្ចុប្បន្នជា ទណ្ឌិត (នៅក្នុងពន្ធនាគារខេត្តរតនគិរី) ។

**សូមគោរពជូន**
**លោក ប្រធាន សាលាដំបូងខេត្តរតនគិរី**

**សូមទានជ្រាប!**

**តាមរយៈ៖** លោកប្រធានលេខាធិការដ្ឋានសាលាដំបូងខេត្តរតនគិរី

**កម្មវត្ថុ៖** សុំប្តឹងឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម

-លែងលះប្តីឈ្មោះ ....................

-សុំសិទ្ធគ្រប់គ្រងកូន ប្រុស ស្រី ចំនួន ០២ នាក់

អង្គហេតុ មូលហេតុចាំបាច់បញ្ជាក់អំពីការទាមទារ

តបតាមអង្គហេតុ មូលហេតុ និងកម្មវត្ថុខាងលើនាងខ្ញុំសូមគោរពជម្រាបជូនលោក **ប្រធាន** មេត្តាជ្រាបថា៖ នាងខ្ញុំបានរួមរស់ជាមួយ និងភាគីប្តី ក្នុងឆ្នាំ ២០១៧ តាមប្រពៃណី ដោយមិនមានការបញ្ជាក់ និងចុះសំបុត្រអាពាហ៍ពិពាហ៍អ្វីឡើយ មានតែប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ តែប៉ុណ្ណោះ។

រយៈពេលរួមរស់និងគ្នាក្នុងគ្រួសារ មិនមានការគោរពសិទ្ធគ្នាជាប្តីប្រពន្ធ និងចុងក្រោយនេះភាគីប្តីបានប្រើប្រាស់គ្រឿងញៀន ត្រូវបានតុលាការផ្តន្ទាទោសតាមផ្លូវច្បាប់ ។

ដើម្បីជៀសវាងបញ្ហាផ្សេងៗដែលកើតមានក្នុងគ្រួសារតទៅទៀត នាងខ្ញុំសុំដាក់ពាក្យបណ្តឹងមកលោក ប្រធាន សុំចេញសាលក្រមតាមកម្មវត្ថុខាងលើ ដើម្បីបានបញ្ចប់បញ្ហាគ្រួសារដោយសន្តិវិធីតាមច្បាប់ ។

### ឯកសារភ្ជាប់

-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

-សៀវភៅគ្រួសារ

-សៀវភៅស្នាក់នៅ

-សំបុត្របញ្ជាក់កំណើត កូនស្រីឈ្មោះ ....................

-សំបុត្របញ្ជាក់កំណើត កូនប្រុសឈ្មោះ ........................

-អត្តសញ្ញាណប័ណ្ណ ០១ សន្លឹក

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមលោក **ប្រធាន** មេត្តាទទួលពាក្យបណ្តឹងរបស់នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូមលោក **ប្រធាន** មេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ៕

ថ្ងៃ សុក្រ ៧ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរតនគិរី,ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២០

**ស្នាមមេដៃស្តាំ**

............................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

<table>
<tr><td colspan="2">បង្គាប់មកចុងចម្លើយឈ្មោះ .......... ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។ មានលេខទូរស័ព្ទ៖ ០៣១ ៦៦៦៦ ៥២៨</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និងភាគី)</td><td>សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៧៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ........................ ចុងចម្លើយ: ........................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក<br>បន្ទប់ស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល ☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br><br>ថ្ងៃ.............................. ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤<br>ធ្វើនៅរតនគិរី, ថ្ងៃទី............. ខែ មិថុនា ឆ្នាំ២០២០<br>**ចៅក្រម**</td></tr>
</table>

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។
-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

| | |
|---|---|
| បង្គាប់មកដើមចោទឈ្មោះ ............. ភេទស្រី អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគរ។ មានលេខទូរស័ព្ទ៖ ០៩៧ ៧៦០ ៨៥ ៩៣ | |
| សញ្ញាណនៃរឿងក្តី (លេខ និងភាគី) | សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៧៥ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ................. ចុងចម្លើយ: ......................... |
| កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក<br>បន្ទប់ស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី |
| ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់) | ១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ<br>(សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់) | |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៨០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ៣.៩៨៩$ (បីពាន់ប្រាំបួនរយកៅសិបប្រាំបួនដុល្លាអាមេរិក)។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |
| សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃ............................ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤<br>ធ្វើនៅរតនគិរី, ថ្ងៃទី.............ខែមិថុនា ឆ្នាំ២០២០<br>**ចៅក្រម** | |

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។
-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តរតនគិរី
លេខ ................./២០

# ដីកាបញ្ជូន

## ផ្ញើជូន
## លោក អធិការនៃអធិការដ្ឋាននគរបាលស្រុកអូរយ៉ាដាវ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | គោលដៅ |
|---|---|---|---|
| ០១ | -ដីកាកោះ ដើមបណ្ដឹង<br>ឈ្មោះ ........................ | ០២ ច្បាប់ | ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្តន៍។ |
| ០២ | -ដីកាកោះ ចុងចម្លើយ<br>ឈ្មោះ ........................ | ០២ ច្បាប់ | |
| | សរុបចំនួន | ០៤ច្បាប់ | |

ថ្ងៃ........................... ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅរតនគិរី,ថ្ងៃទី............ ខែមិថុនា ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរ**

**បានទទួល**
ធ្វើនៅរតនគិរី,ថ្ងៃទី................ខែកុម្ភៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី
លេខ.............................

## កំណត់ហេតុស្តីពីនីតិវិធីត្រៀម
## សម្រាប់ការទាយហេតុផល

បានឃើញមាត្រា១០៩,១១០,១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

## សង្ខេបរឿងក្តី

ប្តឹងសុំឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម៖

១. សុំផ្តាច់ នីតិសង្វាសឈប់រួមរស់ជាមួយគ្នា រំលាយសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិនៅក្នុងក្រុមហ៊ុន និងទទួលខុសត្រូវលើបំណុលទាំងអស់ ។

៤. ប្រគល់ដីលំនៅដ្ឋានចំនួន ០២កន្លែង និងរថយន្តចំនួន ០១គ្រឿង ជូនទៅភាគីប្តី ។

លោក .................... ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

លោក ........................ ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

ដើមបណ្តឹងឈ្មោះ ................ ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មុខរបរ អាជីវករគ្រប់គ្រងរថយន្តដឹកអ្នកដំណើរ លេខទូរស័ព្ទ ០៩៧ ៧៦០ ៤៥ ៩៣ មានមេធាវីតំណាងដោយអណត្តិ ........................ ។

**ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងប្រាំបួន និងសូន្យ១នាទីព្រឹក** នៅសាលាដំបូងខេត្តរតនគិរី

**ស.ឆ** ដើមបណ្តឹងឈ្មោះ .................... បានឆ្លើយបញ្ជាក់ថា នាងខ្ញុំសុំអោយ លោកចៅក្រម ចេញសេចក្តីសម្រេច តាមពាក្យបណ្តឹងរបស់នាងខ្ញុំ ចុះថ្ងៃទី៣១.០៥.២០២០ ក្នុងការលែងលះ បែងចែកទ្រព្យរួម សងបំណុល និងសិទ្ធិគ្រប់គ្រងកូន ដោយមូលហេតុ នាងខ្ញុំនឹងប្តី រស់នៅមិនចុះសម្រុងនឹងគ្នា ទើបសម្រេចចិត្តលែងលះគ្នាតាមផ្លូវច្បាប់ ហើយក្នុងពេលនេះ ប្តីនាងខ្ញុំក៏បានព្រមព្រៀងតាមពាក្យបណ្តឹងនេះដែរ ។

**ស.ឆ** មេធាវី លោក .......... បានឆ្លើយបញ្ជាក់ថា កូនក្តីរបស់ខ្ញុំបាទពិតជារស់នៅមិនចុះសម្រុងជាមួយនឹងភាគីប្តី ហើយមានបញ្ហាក្នុងគ្រួសារគ្រប់បែបយ៉ាង ទើបមកពឹងពាក់រូបខ្ញុំបាទជាមេធាវី ដាក់ពាក្យបណ្តឹងមកតុលាការ ដោយសុំលែងលះ បែងចែកទ្រព្យរួម សងបំណុល និងសិទ្ធិគ្រប់គ្រងកូន ហើយភាគីប្តីក៏បានព្រមព្រៀងគ្នា ហេតុនេះសុំឲ្យលោកចៅក្រម សម្រេចសេចក្តីតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក បានអានអោយដើមបណ្តឹង មេធាវី ស្តាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្តិតមេដៃទុកជាភស្តុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **ដើមបណ្តឹង** **មេធាវី**

........................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី
លេខ........................

## កំណត់ហេតុស្ដីពីនីតិវិធីត្រៀម
## សម្រាប់ការទាយហេតុផល

បានឃើញមាត្រា១០៩,១១០,១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

### សញ្ញាណរឿងក្ដី

ប្ដឹងសុំឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម៖

១. សុំផ្ដាច់ នីតិសង្វាសឈប់រួមរស់ជាមួយគ្នា រំលាយសំបុត្រអាពាហ៍ពិពាហ៍ ០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិនៅក្នុងក្រុមហ៊ុន និងទទួលខុសត្រូវលើបំណុលទាំងអស់ ។

៤. ប្រគល់ដីលំនៅដ្ឋានចំនួន ០២កន្លែង និងរថយន្តចំនួន ០១គ្រឿង ជូនទៅភាគីប្ដី ។

លោក .................. ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

លោក ...................... ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

ចុងចម្លើយឈ្មោះ .................... ភេទ ប្រុស អាយុ ៤១ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មុខរបរ មន្ត្រីកងរាជអាវុធហត្ថ លេខទូស័ព្ទ ០៣១ ៦៦៦ ៦៥ ២៨ ។

**ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងដប់ និងសូន្យ១នាទីព្រឹក** នៅសាលាដំបូងខេត្តរតនគិរី

**ស.ឆ** ចុងចម្លើយ បានឆ្លើយបញ្ជាក់ថា ខ្លួនឯកភាពតាមការលើកឡើងរបស់ដើមបណ្ដឹង និងការបញ្ជាក់របស់លោកមេធាវី ដើម្បីបានបញ្ចប់បញ្ហាគ្រួសារតាមច្បាប់ដោយសន្តិវិធី ។

**ស.ឆ** ចំពោះទ្រព្យសម្បត្តិរួម ប្រាក់បំណុល ឯកភាពតាមពាក្យបណ្ដឹង ចំពោះកូនមានចំនួន ០២នាក់ ឯកភាពប្រគល់ជូនភាគីប្រពន្ធតាមការស្នើសុំ តែខ្លួនសុំសិទ្ធិទំនាក់ទំនង និងសួរសុខទុក្ខកូន ហេតុនេះ សុំលោក ចៅក្រម ចេញសេចក្ដីសម្រេចតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុនៃនីតិវិធីសេចក្ដីបញ្ជាក់ដំបូងនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោងដប់ និងសាមសិបនាទីព្រឹក បានអានអោយចុងចម្លើយស្ដាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្ដិតមេដៃទុកជាភស្តុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **ចុងចម្លើយ**

......................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
**មន្ទីរសើុបសួរ ទី១**

## កំណត់ហេតុស្ដីពីនីតិវិធីសាកសួរសាម៉ីភាគី

(មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

| សញ្ញាណរឿងក្ដី | បណ្ដឹងលេខ ...... ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២០<br>បណ្ដឹងលែងលះជានីតិសង្វាស |
|---|---|
| កាលបរិច្ឆេទ | ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២០<br>វេលាម៉ោងប្រាំបួន និងសូន្យ១នាទីព្រឹក |
| កន្លែងបើក/បិទ | **សាលាដំបូងខេត្តរតនគិរី** |
| ចៅក្រម | លោក ................................ |
| ក្រឡាបញ្ជី | លោក ................................ |
| ភាគីដែលបានបង្ហាញខ្លួន | -ដើមបណ្ដឹងឈ្មោះ ........................ ភេទស្រី អាយុ ៣៧ ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។<br>-ចុងចម្លើយឈ្មោះ ........................ ភេទប្រុស អាយុ ៤១ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។ |

### សេចក្ដីថ្លែងការណ៍របស់ភាគីមានដូចខាងក្រោម៖

**ស.ឆ ៖** ភាគីដើមបណ្ដឹង បានឆ្លើយបញ្ជាក់ថា ខ្លួនសុំឲ្យ លោកចៅក្រម ចេញសាលក្រម មានខ្លឹមសារដូចខាងក្រោម៖

១. សុំផ្ដាច់នីតិសង្វាសពីភាគីប្ដី និងរំលាយសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

- ឈ្មោះ ........................ ភេទ ស្រី អាយុ ១៤ឆ្នាំ
- ឈ្មោះ ........................ ភេទ ប្រុស អាយុ ១១ឆ្នាំ

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិមាន

- គ្រប់គ្រងក្រុមហ៊ុន និងរថយន្តដឹកអ្នកដំណើរគ្រប់សាខាទាំងអស់ ឈ្មោះ រតនសម្បត្តិ
- ប្រព័ន្ធលេខទូរស័ព្ទគ្រប់លេខទាំងអស់ប្រើប្រាស់ក្នុងក្រុមហ៊ុនសព្វថ្ងៃ
- ទទួលរ៉ាប់រងសងបំណុលធនាគារអេស៊ីលីដា ចំនួន ៤៥ម៉ឺនដុល្លារអាមេរិក

- បំណុលបុគ្គលផ្សេងៗមានចំនួន ៣៥ម៉ឺនដុល្លារអាមេរិក
- សុំសិទ្ធិគ្រប់គ្រងដីចំនួន ០២កន្លែង

១. ដីស្ថិតនៅយាយទូលចេក មានទំហំ ៤០មX៤០ម ស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី

២. ដីផ្លូវទៅយក្ខឡោម មានទំហំ ១២មX២៥ម ស្ថិតនៅភូមិភ្នំ សង្កាត់យក្ខឡោម ក្រុងបានលុង ខេត្តរតនគិរី ។

ដោយមូលហេតុថានាងខ្ញុំ និងប្តី រស់នៅមិនចុះសម្រុងនឹងគ្នា ទើបនាងខ្ញុំសម្រេចចិត្ត ពឹងសុំឲ្យ លោកមេធាវី ដាក់ពាក្យបណ្តឹងមកតុលាការដើម្បីបញ្ចប់ការលែងលះ បែងចែកទ្រព្យ សងបំណុល និងសិទ្ធិគ្រប់គ្រងកូន តាមផ្លូវច្បាប់ ។

**ស.ឆ** ក្នុងការលែងលះនេះ នាងខ្ញុំសុំប្រគល់ទ្រព្យសម្បត្តិជូនភាគីប្តីដូចខាងក្រោម៖

- រថយន្ត ០១គ្រឿង ម៉ាក TOYOTA REALLY ពណ៌ស ផលិតឆ្នាំ២០២០ ផ្លាកលេខ : ភ្នំពេញ BH.9973 ។
- ផ្ទះល្វែង ០១ល្វែង ស្ថិតនៅ **បុរី លឹម ប៊ុណ្ណា** ភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

**ស.ឆ** ចុងចម្លើយ បានឆ្លើយបញ្ជាក់ថា ខ្លួនយល់ព្រមលែងលះ និងទទួលយកទ្រព្យសម្បត្តិពីដើមបណ្តឹង ដែលបានផ្តល់ជូន និងផ្តល់សិទ្ធិអំណាចមេបាលើកូន ជូនភាគីប្រពន្ធ តែខ្លួនសុំសិទ្ធិទំនាក់ទំនងសួរសុខទុក្ខ ។ ហេតុនេះសុំ លោកចៅក្រម ចេញសេចក្តីសម្រេចតាមផ្លូវច្បាប់ ដោយខ្ញុំបាទយល់ព្រមទទួលយកគ្រប់បែបយ៉ាង ។

**ស.ឆ** មេធាវី របស់ដើមបណ្តឹង បានឆ្លើយបញ្ជាក់ថា ខ្លួនសុំអោយលោកចៅក្រមចេញសេចក្តីសម្រេចជូនកូនក្តីរបស់ខ្ញុំបាទ តាមការលើកឡើងខាងលើ ដោយហេតុថា ភាគីប្តីប្រពន្ធ មានគោលបំណង និងឆន្ទៈ លែងលះគ្នាយ៉ាងពិតប្រាកដ ។ ម្យ៉ាងវិញទៀត កូនក្តីរបស់ខ្ញុំបាទ និងចុងចម្លើយ បានឯកភាពគ្នាលើការបែងចែកទ្រព្យ សងបំណុល សិទ្ធិគ្រប់គ្រងកូន រួចរាល់អស់ហើយ ហេតុនេះ សុំ លោកចៅក្រម សម្រេចតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុស្តីពីនីតិវិធីសាកសួរសាម៉ីភាគី ដោយមានការឯកភាពគ្រប់ចំណុច ។

ឈប់សួរ អានឲ្យសាម៉ីភាគី និងមេធាវី ស្តាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្តិតមេដៃទុកជាភស្តុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **មេធាវី** **ដើមបណ្តឹង** **ចុងចម្លើយ**

.................... ....................

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ......

ចុះថ្ងៃទី ខែ ឆ្នាំ

**សាលក្រមលេខ:**

ចុះថ្ងៃទី ខែ ឆ្នាំ

*តាងនាមប្រជារាស្ត្រខ្មែរ*

**សាលាដំបូងខេត្តកណ្ដាល**

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់

នៅថ្ងៃទី ខែ ឆ្នាំ

ដោយមានសមាសភាព:

-លោក **ជួន ចណ្ណា:** ចៅក្រម

-លោក **ឃី អៀង** ក្រឡាបញ្ជី

-ដើមចោទឈ្មោះ ...................... ភេទ ...... កើតនៅឆ្នាំ ...... ជនជាតិខ្មែរ មុខរបរកស៊ីបុគ្គលិកក្រុមហ៊ុន អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

-មានលោក ........ ជាមេធាវីតំណាងដោយអាណត្តិ ។

ចុងចម្លើយឈ្មោះ ........ ភេទ ... កីតនៅឆ្នាំ ...... ជនជាតិខ្មែរ មុខរប មេផ្ទះ អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

១-*<u>ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:</u>*

១-សុំលែងលះពីប្រពន្ធឈ្មោះ ....... ។

២-សុំសិទ្ធិគ្រប់គ្រងកូន៖

២.១.ឈ្មោះ ............... ភេទ ... កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

២.២.ឈ្មោះ .................. ភេទ ... កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-បែងចែកទ្រព្យសម្បត្តិរួមមាន:ដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ........ ឃុំ ........ ស្រុក ........ ខេត្ត ........ ជាពីរចំណែកស្មើគ្នា។

២-*<u>ការពន្យល់ត្រួសៗអំពីរឿងក្ដី:</u>*

ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ ២០០៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ..... ចុះថ្ងៃទី ..... ខែ ..... ឆ្នាំ ...... នៃសៀវភៅអាពាហ៍ពិពាហ៍លេខ .......... ។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍អ្នកទាំងពីររស់នៅជាមួយគ្នាមានកូនចំនួន ០២នាក់ មានឈ្មោះ ............ ភេទ ... កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ .............. ភេទ ..... កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

ប៉ុន្តែក្រោយពេលដែល មានកូន ០២ នាក់ អ្នកទាំងពីរតែងតែមានភាពកាំរកូសជាមួយគ្នាជាញឹកញាប់ ការរស់នៅមិនចុះសម្រុងគ្នា និងបានបែកលំនៅសង្វាសអស់មួយរយៈមកហើយ ជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តី ប្រពន្ធតទៅមុខទៀត។ ហើយក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការ ។

៣-*ការអះអាងរបស់ភាគី*:

-ដើមចោទឈ្មោះ .................... បានអះអាងថា: ខ្លួនប្តឹងសុំឲ្យតុលាការចេញសាលក្រម ដូចការទាមទារខាងលើ ដោយហេតុថា ខ្លួនបានរៀបការជាមួយឈ្មោះ .......... កាលពីថ្ងៃទី ខែ ឆ្នាំ និងបានទៅចុះ សំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ ។ ការរួមរស់នៅជាមួយគ្នាមានកូនចំនួន ០២ នាក់ គឺឈ្មោះ ............. ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ .................. ភេទប្រុស កើតថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៤។ ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ........... ឃុំ ............ ស្រុក ........... ខេត្ត ........... ដែលមានលិខិតលក់ទិញចុះថ្ងៃទី ០៩.០២.២០១២ និងបានឃេញនឯបញ្ជាក់លេខ:០១៨/១២ ចុះថ្ងៃទី ខែ ឆ្នាំ របស់មេឃុំអូរបាក់រទេះ និងផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ...... ...................... ចុះថ្ងៃទី .... ខែ ...... ឆ្នាំ ...... ដែលកំពុងបង់រំលោះនៅធនាគារបានចំនួន ១០ខែ ស្មើទឹកប្រាក់ចំនួន .............................. ដុល្លាអាមេរិក និងមានគ្រឿងអល័ង្កាសរុបស្មើទឹកប្រាក់ចំនួន ...................... ដុល្លាអាមេរិក សូមបញ្ជាក់ថា ពួកខ្លួនពុំមានជំពាក់បំណុលគេទេ ហើយដីខាងលើក៏ពុំមានជាប់ពាក់ព័ន្ធនឹងការធានាបំណុលគេដែរ ។

-ចុងចម្លើយឈ្មោះ .......... បានចូលមកធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្លួនឯកភាពក្នុងការលែងលះ សុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ សុំប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងពីតនាក់ក្នុងមួយខែចំនួន ៣០០$(បីរយ) ក្នុងករណីកូនទាំងពីរនាក់រស់នៅជាមួយខ្លួន និងទទួលស្គាល់ថាមានទ្រព្យសម្បត្តិរួមដូចការលើកឡើងរបស់ដើមចោទប្រាកដមែន។

ក្រោយការផ្សះផ្សាសម្រុះសម្រួលរួចមកគូរភាគីបានឯកភាពគ្នាដូចខាងក្រមះ

-ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ .......... ឃុំអូរ .......... ស្រុក .............. ខេត្ត .............. ដែលមានលិខិតលក់ទិញចុះថ្ងៃទី ...................... និងបានឃើញនិងបញ្ជាក់លេខ: ........ ចុះថ្ងៃទី .... ខែ ... ឆ្នាំ ...... របស់មេឃុំ .......... នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .............................. ...... ចុះថ្ងៃទី .. ខែ .... ឆ្នាំ .... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់រពហារកិច្ចចិញ្ចឹមកូន។

-កូនទីមួយឈ្មោះ .................... ភេទប្រុស និងកូនទីពីរឈ្មោះ ...................... ភេទប្រុស ទុកសិទ្ធិឲ្យកូនគាត់ស្រេចចិត្តដោយខ្លួនគាត់។

-មេធាវីការពារសិទ្ធិដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-មេធាវីការពារសិទ្ធិចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-*__ចំណុចវិវាទ:__* ការលែងលះ និងសិទ្ធិគ្រប់គ្រងកូន។

៥-*__ចំណុចគ្មានវិវាទ__*: ឯកភាពលើការបែងចែកទ្រព្យសម្បត្តិរួម។

## សំអាងហេតុ

១-តាមការអះអាងរបស់គូភាគីឃើញថា ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីកាលពីថ្ងៃទី ..... ខែ ........ ឆ្នាំ ........ និងបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្រ្តីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ........ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ................ ។ ដូច្នេះឃើញថា ដើមចោទ និងចុងចម្លើយ បានបំពេញករណីយកិច្ចជាប្តីប្រពន្ធស្របច្បាប់ ចំពោះការទាមទារសុំលែងលះនេះតុលាការអាចពិចារណាសម្រេចបាន។ តុលាការបានសាកល្បងធ្វើការផ្សះផ្សាគូភាគីរួចហើយ ប៉ុន្តែគូភាគីនៅតែទាមទារលែងលះគ្នា ដោយសារអស់មនោសញ្ចេតនា អាណិតស្រលាញ់គ្នាជាប្តីប្រពន្ធទៀតហើយ ។

២-នៅក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីមានកូនចំនួន ០២នាក់មាន ៖

.ឈ្មោះ ............... ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

.ឈ្មោះ .................... ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-ទ្រព្យសម្បត្តិរួមមាន៖

-ទ្រព្យសម្បត្តិរួមចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ .......... ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............ ឃុំ ............ ស្រុក ............ ខេត្ត ............ ដែលមានលិខិតលក់ទិញចុះថ្ងៃទី ........................... និងបានឃើញនិងបញ្ជាក់លេខ: .......... ចុះថ្ងៃទី ..... ខែ ... ឆ្នាំ របស់មេឃុំ ........................... នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ................................ ....... ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ..... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់អាហារកិច្ចចិញ្ចឹមកូន។

គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-កូនទីមួយឈ្មោះ .................... ភេទប្រុស បានសុំរស់នៅជាមួយម្តាយ និងកូនទីពីរឈ្មោះ ..... ............ ភេទប្រុស បានសុំរស់នៅជាមួយឪពុក គប្បីតុលាការសម្រេចតាមការណ៍ស្នើរសុំ។

យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ យោងតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នាមានសិទ្ធិ

ចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន- ។

៥-ចំពោះប្រាក់ប្រដាប់ក្តីតុលាការគប្បីឲ្យដើមចោទ និងចុងចម្លើយ ទទួលបន្ទុកម្នាក់ពាក់កណ្តាល (មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី )។

## សេចក្តីសម្រេចបញ្ចប់

១-ឲ្យដើមចោទឈ្មោះ ............ លែងលះពីចុងចម្លើយឈ្មោះ ............ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

២-ប្រគល់សិទ្ធិអំណាចមេបាឲ្យទៅ៖

២.១.ដើមចោទឈ្មោះ ............ លើកូនឈ្មោះ ............ ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

២.២.ចុងចម្លើយឈ្មោះ ............ លើកូនឈ្មោះ ............ ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

ទុកសិទ្ធិឲ្យភាគីដែលមិនបានទទួលសិទ្ធិអំណាចមេបាទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូន និងផ្តល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៣-ប្រគល់ទ្រព្យសម្បត្តិរួមមាន៖

៣.១-ដីទំហំ ............ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............ ឃុំ ............ ស្រុក ............ ខេត្ត ............ ដែលមានលិខិតលក់ទិញចុះថ្ងៃទី ............ និងបានឃើញនិងបញ្ជាក់លេខ: ............ ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ...... របស់មេឃុំ ............ ប្រគល់ឲ្យកូនទាំងពីរនាក់គ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែត្រូវភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

៣.២-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

៣.៣-ផ្ទះមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ............ ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ...... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និង ត្រា **ជួន ឧណ្ណា:**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣

ធ្វើនៅខេត្តកណ្តាល,ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

លេខ: ...... /២០២០

**លិខិតបញ្ជាក់សាលក្រមស្ថាពរ**

យើង **ឃី អៀង** ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ...... ចុះថ្ងៃទី ...... ខែ ... ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្ដាល។

បានឃើញ សាលក្រមលេខ: ........ ចុះថ្ងៃថ្ងៃទី ... ខែ ... ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ពាក្យសុំបញ្ជាក់ការចូលជាសាលក្រមស្ថាពរនៃសាលក្រម ចុះថ្ងៃទី ........ ខែ ...... ឆ្នាំ ........ របស់មេធាវីឈ្មោះ .................... ជាមេធាវីតំណាងដោយអាណត្តិរបស់ឲ្យចុងចម្លើយ។

សូមបញ្ជាក់ថា សាលក្រមលេខ: ........ ចុះថ្ងៃទី ... ខែ ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្ដាល បានចូលជាស្ថាពរពីថ្ងៃទី ...... ខែ ... ឆ្នាំ ........ តទៅហើយដោយភាគីពុំបានប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

យើងចេញលិខិតបញ្ជាក់នេះ ដើម្បីអនុញ្ញាតឲ្យដាក់រូបមន្តអនុវត្តលើសាលក្រមនេះ សម្រាប់ភាគីសុំយកទៅអនុវត្តតាមច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣

ខេត្តកណ្ដាល , ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

ឃី . អៀង

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

លេខ: /២០២០

## រូបមន្តអនុវត្តសាលក្រម

យើង **ឃី អៀង** ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ មាត្រា ៣៥៤,៣៥៥ និងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ លិខិតបញ្ជាក់សាលក្រមស្ថាពរលេខ: ចុះថ្ងៃទី ... ខែ ........ ឆ្នាំ របស់ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ពាក្យសុំចុះថ្ងៃទី ... ខែ ........ ឆ្នាំ ........ របស់អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយឈ្មោះ .................. ។

**សូមបញ្ជាក់ពីខ្លឹមសារអនុវត្តដូចខាងក្រោម:**

-ម្ចាស់បំណុល នៃការអនុវត្តឈ្មោះ .................. ភេទ ..... កើតនៅឆ្នាំ ........ អាសយដ្ឋានផ្ទះលេខ៦២E0 ផ្លូវលេខ២(បុរីភិភពថ្មី) ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

-កូនបំណុលនៃការអនុវត្តឈ្មោះ ......... ភេទ ... កើតនៅឆ្នាំ ........ អាសយដ្ឋានផ្ទះលេខ៦២E0 ផ្លូវលេខ២(បុរីភិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

-អនុវត្តតាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ: ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ..... របស់សាលាដំបូងខេត្តកណ្ដាល ដែលបានចូលជាស្ថាពរពីថ្ងៃទី ... ខែ ... ឆ្នាំ ........ គ្រង់ចំណុចទាំងមូលនៃសាលក្រម។

*សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលក្រម ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍ អនុវត្តសាលក្រមនេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។*

ថ្ងៃព្រហស្បតិ៍ ០១ ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ខេត្តកណ្ដាល ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

ឃី.អៀង